# កម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម






Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*ខ្ញុំមិនដឹងថា ខ្ញុំអាចបំភ្លេចរឿងរ៉ាវនេះតាមវិធីណាកើតទេ។ ប៉ុន្មានថ្ងៃនេះ*
*កូនៗរបស់ខ្ញុំចេះតែប្រាប់ខ្ញុំឲ្យបំភ្លេចរឿងរ៉ាវពីអតីតកាល ក៏ប៉ុន្តែខ្ញុំធ្វើមិនបានទាល់តែសោះ។*
*វាលំបាកខ្លាំងណាស់ឲ្យបំភ្លេចរឿងរ៉ាវទាំងអស់នោះ។*

**- ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកស្រី មុម សំអឿន**

## *ជំពូកទី ១ ៖* **ទិដ្ឋភាពទូទៅ**

អង្គជំនុំជម្រះបានចាប់ផ្ដើមបើកសវនាការជាថ្មី ក្រោយការឈប់សម្រាកពេញមួយសប្ដាហ៍ដែលជាថ្ងៃគម្រប់ខួបនៃការឡើងគ្រងរាជ្យរបស់ព្រះមហាក្សត្របច្ចុប្បន្ន និងពិធីបុណ្យចម្រើនព្រះជន្មាយុរបស់អតីតព្រះមហាក្សត្រ ។ សប្ដាហ៍នេះ អង្គជំនុំជម្រះបានស្ដាប់សក្ខីកម្មសាក្សីម្នាក់ ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ និងវេជ្ជបណ្ឌិតជំនាញម្នាក់ ដែលត្រូវបានតុលាការជ្រើសតាំងឲ្យធ្វើបទបង្ហាញស្ដីពីការវាយតម្លៃលើបញ្ហាស្ថានភាពសុខភាព និងបញ្ហាកាយសម្បទារបស់ជនជាប់ចោទ **អៀង សារី** ក្នុងការចូលរួមសវនាការ។ សាក្សី **ស៊ុំ ជា** ធ្លាប់ជាទាហានវ័យក្មេងរបស់ខ្មែរក្រហមនៅក្នុងភូមិភាគឧត្ដរ ។ គាត់បានចូលរួមវាយរំដោះយកទីក្រុងភ្នំពេញជាមួយទាហានខ្មែរក្រហមដទៃទៀត។ រីឯអ្នកស្រី **មុម សំអឿន** បច្ចុប្បន្នជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយមានអតីតភាពជាសាស្ត្រាចារ្យផ្នែកភាសាបារាំង និងក៏ធ្លាប់ជាបុគ្គលិកបម្រើការឲ្យក្រសួងអប់រំនៅក្នុងទីក្រុងភ្នំពេញមុនពេលភ្នំពេញត្រូវបានវាយបែក។ ក្នុងចំណោមការខូចខាត និងការរងទុក្ខវេទនាដែលអ្នកស្រីបានតស៊ូឆ្លងកាត់ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនោះ គឺជាការបាត់បង់ប្ដី និងកូនប្រាំមួយនាក់ក្នុងចំណោមកូនដប់មួយនាក់របស់អ្នកស្រី ។

អង្គជំនុំជម្រះ មិនបានបើកកិច្ចដំណើរការនីតិវិធីនៅថ្ងៃពុធនេះទេ ខណៈពេលដែលភាគីទាំងអស់ត្រូវបានណែនាំឲ្យធ្វើការត្រៀមលក្ខណៈសម្រាប់សវនាការថ្ងៃព្រហស្បតិ៍ ដើម្បីស្ដាប់នូវបទបង្ហាញស្ដីពីបញ្ហាស្ថានភាពសុខភាព និងបញ្ហាកាយសម្បទារបស់លោក **អៀង សារី** ក្នុងការចូលរួមសវនាការ ។ នៅថ្ងៃព្រហស្បតិ៍ វេជ្ជបណ្ឌិតជំនាញផ្នែកសុខភាពមនុស្សចាស់ គឺលោកសាស្ត្រាចារ្យ **ចន ខាំប៊ែល** (John Campbell) បានចូលខ្លួនក្នុងបន្ទប់សវនាការតាមការកោះហៅរបស់អង្គជំនុំជម្រះដើម្បីឆ្លើយតបនឹងសំណួរ និងសេចក្ដីបញ្ជាក់នានាដែលបានទាញចេញពីរបាយ

ការណ៍របស់គាត់ ដែលផ្តោតទៅលើបច្ចុប្បភាពនៃស្ថានភាពសុខភាពរបស់លោក **អៀង សារី** ។ លោកសាស្រ្តាចារ្យ **ខាំប៉ែល** បានរកឃើញថាលោក **អៀង សារី** មានសតិស្មារតីល្អដែលអាចចូលរួមសវនាការបាន ទោះបីជាកាយសម្បទារបស់គាត់ចុះខ្សោយច្រើនជាងមុន បើប្រៀបធៀបទៅនឹងស្ថានភាពពីរខែមុននេះ។ ប្រការនេះ នាំឲ្យអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចបណ្តោះអាសន្នឲ្យលោក **អៀង សារី** វិលត្រឡប់ទៅកាន់មន្ទីរឃុំឃាំង និងបន្តតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំឃាំងវិញ ។ ទោះបីជាយ៉ាងនេះក៏ដោយ លោក **អៀង សារី** បានទទួលការអនុគ្រោះសម្រាប់ខែវិច្ឆិកានេះ ក្នុងការដែលមិនចាំបាច់មានវត្តមានក្នុងបន្ទប់សវនាការដោយសារគាត់បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងលិខិតលះបង់សិទ្ធិតាមដានសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលនៅសល់ក្រោយពីនេះ ។

## *ជំពូកទី ២ ៖* សង្ខេបសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី

សាក្សី **ស៊ុំ ជា** ជាអតីតទាហានខ្មែរក្រហម ត្រូវបានចោទសួរពីការពាក់ព័ន្ធរបស់គាត់ក្នុង *"ការរំដោះ"* ភ្នំពេញ និងការជម្លៀសដោយបង្ខំជាបន្តបន្ទាប់ទៅលើប្រជាពលរដ្ឋដែលរស់នៅភ្នំពេញ ។ ចំណែកដើមបណ្តឹងរដ្ឋប្បវេណីអ្នកស្រី **មុម សំអឿន** បានផ្តល់ព័ត៌មានយ៉ាងលម្អិតជុំវិញបទពិសោធន៍របស់គាត់ក្នុងអំឡុងពេលជម្លៀសដោយបង្ខំទៅលើក្រុមគ្រួសារគាត់ឲ្យចេញពីទីក្រុងភ្នំពេញ និងអំឡុងពេលដែលក្រុមគ្រួសាររបស់គាត់បានរស់នៅតាមបណ្តាខេត្តមួយចំនួនក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។

### ក. សក្ខីកម្ម ស៊ុំ ជា

សក្ខីកម្មរបស់លោក **ស៊ុំ ជា** បានចំណាយពេលពេញមួយថ្ងៃច័ន្ទទៅលើកិច្ចដំណើរការនីតិវិធី។[១] សាក្សីរូបនេះ បានផ្តល់សក្ខីកម្មស្តីពីតួនាទីរបស់គាត់ដែលធ្លាប់ជាទាហានបដិវត្តន៍ខ្មែរក្រហមថ្នាក់ទាបម្នាក់ ។ គាត់បានចាប់ផ្តើមចូលរួមក្នុងចលនាកងទ័ពកាលពីឆ្នាំ១៩៧២ នៃកងវរសេនាតូចមួយដែលក្រុមរបស់លោកបានធ្វើសកម្មភាពវាយលុកជាហូរហែដើម្បីឆ្ពោះទៅកាន់ភ្នំពេញ រហូតដល់វាយបំបែកបានទាំងស្រុងក្នុងខែមេសា ឆ្នាំ១៩៧៥ ។ សំណួរជាច្រើនដែលបានលើកឡើងពីភាគីទាំងអស់ បានផ្តោតទៅលើព្រឹត្តិការណ៍ដែលពាក់ព័ន្ធនឹងទិដ្ឋភាពនៃការជម្លៀសប្រជាពលរដ្ឋភ្នំពេញ ទំនាក់ទំនងនៅក្នុងចំណោមកងកម្លាំងទ័ពតាមតំបន់ផ្សេងៗនៅពេលចូលដល់រាជធានី និងការប្រព្រឹត្តទៅលើអតីតទាហាន **លន់ នល់** និងមន្ត្រីរដ្ឋការនៃរបបនេះពីសំណាក់កងទ័ពខ្មែរក្រហម ។

#### *ក.១. កងពលលេខ១ នៃភូមិភាគឧត្តរ*

លោក **ស៊ុំ ជា** បានកើតនៅឆ្នាំ១៩៥៣[២] ក្នុងស្រុក*ព្រៃឈរ* ខេត្ត*កំពង់ចាម* ។ គាត់បានក្លាយជាទាហានខ្មែរក្រហមដោយស្ម័គ្រចិត្តនៅឆ្នាំ១៩៧២ បន្ទាប់ពីអាមេរិកបានទម្លាក់គ្រាប់បែកក្នុងខេត្តមួយចំនួន ហើយបន្ទាប់ពីការអំពាវនាវរបស់ព្រះអង្គម្ចាស់ **នរោត្តម សីហនុ** តាមវិទ្យុឲ្យ *"ប្រជាពលរដ្ឋរបស់ព្រះអង្គចូលទៅក្នុងព្រៃម៉ាគី"* **ដើម្បីតស៊ូប្រឆាំងនឹងរបប លន់ នល់** ។ លោក **ស៊ុំ ជា** បានធ្វើជាទាហានក្នុងកងពលលេខ១ នៃភូមិភាគឧត្តរក្រោមការដឹកនាំរបស់បុគ្គលម្នាក់ឈ្មោះ **រឿង** ។ លោក **ស៊ុំ ជា** បានរៀបរាប់បន្ថែមទៀតថា គាត់បានទទួលការហ្វឹកហាត់អប់រំពីឈ្មោះ **រឿង** និងពីមេភូមិដទៃទៀតដែលខ្លឹមសារនៃការបង្រៀនប្រជាជន គឺឲ្យមានអារម្មណ៍ឈឺចាប់នឹងការទម្លាក់គ្រាប់បែករបស់អាមេរិក ក៏ដូចជាចងចាំ *"សត្រូវ"* ដែលជាបក្សពួករបស់ **លន់ នល់**។ ដោយចេញដំណើរពីប៉ែកខាង

ត្បូងនៃទីរួម *ខេត្តកំពង់ចាម* កងពលតូចរបស់គាត់បានធ្វើការវាយប្រយុទ្ធនៅតាមតំបន់ *ស្គន់ ថ្នល់កែង ព្រែកក្តាម ស្ពានតាថា* រហូតទាល់តែមកដល់តំបន់ភ្នំ *បាសិត* ប៉ែកខាងត្បូងនៃរាជធានី ។ គាត់បានអះអាងថា គាត់មិនដែលបានទទួលឋានៈ ឬមុខតំណែងអ្វីឡើយនៅចន្លោះឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៥ ។ នៅមុនការវាយបំបែកភ្នំពេញ លោក **ស៊ុំ ជា** និងទាហានក្នុងកងពលដែលនៅជាមួយគាត់ដទៃទៀត បានឈរជើងប្រហែលពីរខែក្នុងតំបន់ភ្នំ *បាសិត* ។ សាក្សីបានរម្លឹកឡើងវិញថា នៅពេលដែលពួកគាត់បានចាប់ផ្តើមវាយភ្នំពេញក្នុងឆ្នាំ១៩៧៥[៣] កងពលតូចរបស់គាត់បានចល័តទៅប៉ែកខាងត្បូងចេញពីភ្នំ *បាសិត* ទាំងយប់ដោយបានឆ្លងកាត់តាមស្រុក *ឃ្លួញ* និងបន្តឆ្ពោះទៅកាន់ *ទួលគោក* ក្នុងរាជធានីភ្នំពេញ ។

## *ក.២. ការរំដោះ និងការជម្លៀសប្រជាជនចេញពីភ្នំពេញ*

នៅពេលបានមកដល់ភ្នំពេញ លោក **ស៊ុំ ជា** បានឃើញទីក្រុងមាន *“សភាពច្របូកច្របល់”* និងវឹកវរ រួមជាមួយនឹងស្នូរកាំភ្លើងគ្រប់ទីកន្លែង រីឯប្រជាជនបាននាំគ្នាកាន់ទង់ជ័យ ខ្លះទៀតគ្រវីក្រណាត់ពណ៌ស សម្តែងនូវការអបអរនៅពេលដែលក្រុមពួកគាត់កំពុងដើរតាមដងផ្លូវនៅក្នុងក្រុង ។ លោក **ស៊ុំ ជា** និងទាហានដែលរួមដំណើរជាមួយគ្នាពេលនោះ មិនអាចចំណាំថាមួយណាជាអតីតទាហាន **លន់ នល់** បាននោះទេ នៅពេលដែលទាហានទាំងនោះបានផ្លាស់ប្តូរឯកសណ្ឋាន និងមើលទៅដូចជនស៊ីវិលធម្មតា ។ សាក្សីរូបនេះ ព្រមទាំងកងទាហានខ្មែរក្រហមដទៃទៀត បានទទួលបទបញ្ជាពីមេបញ្ជាការកងវរសេនាតូចដែលមានឈ្មោះ **ហាក់** ឲ្យជម្លៀសប្រជាជននៅក្នុងក្រុងចេញទាំងអស់ក្នុងរយៈពេលប្រាំពីរថ្ងៃដើម្បីបោសសម្អាតទីក្រុង ។ តាមរយៈការប្រជុំជាមួយមេបញ្ជាការ **ហាក់** ស្តីពីផែនការវាយបំបែកភ្នំពេញ លោក **ស៊ុំ ជា** បានបញ្ជាក់ពីការជឿជាក់របស់គាត់ថា បទបញ្ជាទាំងនេះគឺចេញមកពីថ្នាក់លើ។[៤] សាក្សីត្រូវបានគេប្រាប់ថា ប្រសិនបើប្រជាជនជំទាស់នឹងការចាកចេញ *“គាត់ត្រូវតែធ្វើអ្វីក៏ដោយឲ្យតែប្រជាជនទាំងនោះចាកចេញ”* ។ សាក្សីដដែលនេះ បាននិយាយថាប្រជាជនដែលនៅក្រោមការត្រួតត្រារបស់កងពលរបស់គាត់មិនបានជំទាស់មិនព្រមចេញនោះទេ ដូច្នេះហើយ ការធ្វើទុក្ខបុកម្នេញមិនមានសារៈសំខាន់អ្វីឡើយចំពោះប្រជាជនទាំងនោះ ។ ទោះបីជាយ៉ាងក៏ដោយ គាត់បានផ្តល់សក្ខីកម្មថា ប្រជាជនដែលរស់នៅក្នុងតំបន់ដទៃទៀតក្នុងទីក្រុងមិនចង់ចាកចេញនោះទេ ហើយថាប្រជាជនទាំងនោះបានប្រឈមមុខនឹងការបង្ខិតបង្ខំយ៉ាងឃោរឃៅដោយកងទាហានដទៃទៀត និងជួនពេលខ្លះ អ្នកជម្លៀសទាំងនោះត្រូវគេបង្ខំដោយភ្ជង់កាំភ្លើងគំរាមក៏មាន ។ នៅក្នុងទិដ្ឋភាពបែបនេះ លោក **ស៊ុំ ជា** បានអះអាងក្នុងសេចក្តីថ្លែងការណ៍របស់គាត់ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេតថា គាត់បានឮតៗគ្នាថា*“កងទ័ពនៅតំបន់ភូមិភាគបូព៌ាឃោរឃៅជាទីបំផុត”* ។[៥] សាក្សីបាននិយាយថា គាត់មិនឃើញឧបត្តិហេតុនៃការធ្វើទុក្ខបុកម្នេញណាមួយដោយផ្ទាល់ភ្នែកនោះទេ ក៏ប៉ុន្តែ លោកមេបញ្ជាការ **ហាក់** បានប្រាប់នូវរឿងរ៉ាវទាំងអស់នោះដល់គាត់ ដោយនិយាយថា *“បើមិនបានធ្វើបាបខ្លះទេធ្វើម៉េចទៅរួច”* ។ ដើម្បីឲ្យប្រជាជនព្រមចេញពីក្រុង កងទ័ពខ្មែរក្រហមបានប្រាប់ប្រជាជនថា ត្រូវតែចាកចេញក្នុងរយៈពេលបួនថ្ងៃ ដើម្បីរួចផុតពីការវាយប្រហារ ឬការទម្លាក់គ្រាប់បែករបស់អាមេរិកកាំង ។ សាក្សីរូបនេះបានបញ្ជាក់ថា បន្ទាប់ពីប្រាំទៅប្រាំមួយថ្ងៃក្រោយមក ប្រជាជនទាំងអស់បានចាកចេញពីភ្នំពេញដោយពុំមានសេសសល់ឡើយ ។

### *ក.៣. កិច្ចការកងទ័ពនៃភូមិភាគឧត្តរ*

លោក **ស៊ុំ ជា** បានពន្យល់ថា លោកមេបញ្ជាការ **ហាក់** បានដាក់បញ្ជាឲ្យគាត់ធ្វើការជម្លៀសប្រជាជន ហើយកងពលគាត់ទទួលខុសត្រូវក្នុងការជម្លៀសប្រជាជនស៊ីវិលនៅប៉ែកខាងជើង*ផ្សារថ្មី* ទៅកាន់*ស្ពានជ្រោយចង្វារ* ដើម្បីឲ្យអ្នកជម្លៀសធ្វើដំណើរឆ្ពោះទៅផ្លូវ*គីឡូលេខប្រាំបួន* តាមបណ្តោយផ្លូវជាតិលេខប្រាំ ។ សាក្សីបានបញ្ជាក់ថា កងទ័ពភូមិភាគខាងជើងត្រូវបានឈរជើងនៅតាមបណ្តោយដងផ្លូវក្បែរ*ស្ថានទូតបារាំង* និងបានសម្តាងថា គាត់ *"មិនឃើញមានពួកបារាំង"* នៅក្នុងស្ថានទូតទេ(សំដៅទៅលើជនជាតិបារាំង ឬជនជាតិបរទេស) ហើយស្ថានទូតទៀតសោត ក៏នៅទំនេរស្ងាត និងមានសភាពស្ងប់ស្ងាត់ មានតែវត្តមានទាហានខ្មែរក្រហមតែប៉ុណ្ណោះ ។ សាក្សីបានបន្ថែមថា គាត់ត្រូវបានគេចាត់តាំងឲ្យឈរជើងក្នុងមន្ទីរពេទ្យ*កាល់ម៉ែត* ក្បែរស្ថានទូតបារាំងជាទីកន្លែងដែលគាត់បានឃើញប្រជាជនកំពុងព្យាយាមយកសាច់ញាតិជាអ្នកជម្ងឺចេញពីមន្ទីរពេទ្យជាមួយនឹងរទេះរុញមួយចំនួន ដោយសារអ្នកទាំងនេះ ក៏តម្រូវឲ្យត្រូវចាកចេញពីទីក្រុងដែរ ។ សាក្សីបានពន្យល់ថា មានពេទ្យយោធាខ្មែរក្រហមមួយចំនួនបានចូលក្នុងមន្ទីរពេទ្យ ដើម្បីដើរប្រមូលយកថ្នាំពេទ្យសម្រាប់ទុកព្យាបាលឲ្យពួកទាហានខ្លួននៅក្នុងមន្ទីរ*ពេទ្យធំ* ក្នុងគោលបំណងសម្រាប់បម្រើឲ្យយោធាមានរបួស។ ទោះបីជាយ៉ាងនេះក្តី លោក **ស៊ុំ ជា** ក៏បានបញ្ជាក់ផងដែរថា បុគ្គលិកពេទ្យ និងវេជ្ជបណ្ឌិតដែលបម្រើការឲ្យមន្ទីរពេទ្យ*កាល់ម៉ែត* បានទុកអ្នកជម្ងឺចោល និងរត់គេចខ្លួនបាត់នៅមុនពេលដែលគាត់បានមកដល់ ។ នៅពេលជនភៀសខ្លួនស្នើសុំឲ្យទាហានក្នុងកងវរសេនាតូចផ្តល់ព័ត៌មាន ឬក៏ប្រាប់ពួកគាត់ពីទីកន្លែងដែលអាចស្វែងរកចំណីអាហារ និងទឹកស្អាតទុកបរិភោគដើម្បីអាចធ្វើដំណើរបាន សាក្សីបានឆ្លើយថា *"អត់ដឹងទេសូម្បីតែទ័ពហ្នឹង មិនចង់មានបាយហូបផង ម៉េចហ្នឹងអាចយកអង្ករអីណាទៅឲ្យអីណាកើត"* ។

### *ក.៤. ការចាប់ខ្លួនអតីតទាហាន លន់ នល់*

តំណាងសហព្រះរាជអាជ្ញា បានយោងទៅលើបទសម្ភាសន៍របស់លោក **ស៊ុំ ជា** ជាមួយបុគ្គលិកការិយាល័យសហចៅក្រមស៊ើបអង្កេត ជាសម្អាងក្នុងការចោទសួរសាក្សី ត្រង់ចំណុចដែលគាត់ធ្លាប់បានឆ្លើយពីមុនថា *"បន្ទាប់ពីប្រាំពីរ ឬប្រាំបីថ្ងៃក្រោយមក (ខ្មែរក្រហម) បានដាក់ម៉ែក្រូហ្វូនប្រកាសថា ឲ្យតែទាហាន **លន់ នល់** ត្រូវចូលមកធ្វើការនៅកន្លែងដើមវិញ"* ។ សាក្សីរូបនេះ បានចងចាំថាមានបុរសម្នាក់ឈ្មោះ **គឿន** បានប្រាប់គាត់ពីគម្រោងការណ៍នេះ និងថាខ្លួនគឺជាអ្នកដឹកនាំការកម្ទេចទាហាន **លន់ នល់** ។ តាមរយៈសក្ខីកម្មរបស់សាក្សី **ស៊ុំ ជា** ខ្មែរក្រហមបានបង្កើតកន្លែងប៉ុស្តិ៍ត្រួតពិនិត្យនៅគល់ស្ពាន*ជ្រោយចង្វារ* និងមួយទៀតនៅម្តុំ*ផ្សារថ្មី* ដើម្បីត្រួតពិនិត្យរកទាហាន **លន់ នល់** ។ សាក្សីបានឲ្យដឹងថា អ្នកដែលព្យាយាមលាក់ពីអតីតកាលខ្លួនត្រូវបានទាហានខ្មែរក្រហមស្រាវជ្រាវរក ហើយបន្ទាប់ពីរកឃើញប្រវត្តិរូបរបស់អ្នកទាំងនេះ ក៏ត្រូវបានគេស្វែងរកតាមរយៈការបិទប្រកាសតាមទីសាធារណៈ និងផ្សាយរកឈ្មោះតាមឧបករណ៍បំពងសម្លេង (ម៉ែក្រូហ្វូនដៃ) ។ សាក្សីបានបន្តថា កម្មាភិបាល **គឿន** បានបញ្ជូនឡានកាមីញ៉ុងដែលធ្លាប់បានប្រើដោយកងទ័ព **លន់ នល់** ដើម្បីប្រមូលទាហាន **លន់ នល់** និងដឹកទៅសម្លាប់ចោលនៅម្តុំ*ព្រែកព្នៅ* ។ លោក **ស៊ុំ ជា** បានអះអាងបន្ថែមទៀតថា គាត់ក៏បានដឹងពីប្រតិបត្តិការកម្ទេចនាយទាហាន **លន់ នល់** នៅម្តុំ *ទួលគោក* ផងដែរ។

### *ក.៥.    បន្ទាប់ពីនិទាឃរដូវឆ្នាំ១៩៧៥: តួនាទី និងការងារនៅក្រៅក្រុងភ្នំពេញ*

ក្រោយពីបានបំពេញភារកិច្ចមួយចំនួននៅភ្នំពេញ លោក **ស៊ុំ ជា** ត្រូវបានបញ្ជូនត្រឡប់ទៅកាន់ភ្នំ*បាសិត*វិញ និងក្រោយមកទៀតទៅស្រុក*ទួលសង្កែ* ដើម្បីសង់ទំនប់ទឹក និងជីកប្រឡាយ ក៏ដូចជាចូលរួមធ្វើស្រែចម្ការជាដើម ។ល។ គាត់បានពន្យល់ថា *"ទាហានទាំងអស់ ត្រូវបានគេប្រើដូចសត្វគោក្របីអីចឹង"* ។ គាត់ត្រូវបានគេដកហូតអាវុធ និងចាត់ទុកជា *"ប្រជាជនសាមញ្ញ"* ហើយបង្ខំឲ្យធ្វើការងារបង្កបង្កើនផល ។ នៅអំឡុងពេល *"រំដោះ"* ភ្នំពេញ គាត់បានដឹងត្រឹមតែថា ព្រះមហាក្សត្រ **នរោត្តម សីហនុ** គឺជាថ្នាក់ដឹកនាំនៃចលនាតស៊ូរំដោះ ក៏ប៉ុន្តែក្រោយពីបានចូលរួមក្នុងមហាសន្និបាតមួយនៅពហុកីឡាដ្ឋាន*អូឡាំពិក* រួចមក ទើបសាក្សីបានស្គាល់ពីថ្នាក់ដឹកនាំមួយចំនួនរបស់រដ្ឋាភិបាលថ្មីមួយនេះ ក្នុងនោះមានលោក **ប៉ុល ពត** ត្រូវបានទទួលស្វាគមន៍យ៉ាងគគ្រឹងគគ្រេងនៅពេលនោះ ។[៦]

### *ក.៦.    ឥរិយាបថ និងភាពជឿជាក់បានរបស់សាក្សី*

ក្រុមមេធាវីការពារក្តី បានរិះរកមធ្យោបាយច្រានចោលនូវសេចក្តីថ្លែងការណ៍មួយចំនួនរបស់លោក **ស៊ុំ ជា** ហើយដែលតាមរយៈការសួរដេញដោលជាបន្តបន្ទាប់បានបង្ហាញឲ្យឃើញថា សាក្សីរូបនេះមិនបានឃើញផ្ទាល់ភ្នែកគាត់ឡើយនូវព្រឹត្តិការណ៍ដែលគាត់បានរៀបរាប់ជាច្រើនកន្លងមក ។ ជាឧទាហរណ៍ សាក្សីមិនបានសង្កេតថាតើទាហានខ្មែរក្រហមប្រើប្រាស់ឧបករណ៍បំពងសម្លេងដើម្បីប្រកាសរកចាប់ទាហាន **លន់ នល់** យ៉ាងណានោះក៏គាត់មិនបានដឹង ក៏ប៉ុន្តែគាត់បានផ្តល់សក្ខីកម្មថា ការតាមចាប់នេះ គឺជាគោលការណ៍ទូទៅរបស់ខ្មែរក្រហមទៅវិញ ។ សេចក្តីថ្លែងការណ៍ប្រភេទនេះ បាននាំឲ្យក្រុមមេធាវីការពារក្តីចាត់ទុកសក្ខីកម្មរបស់សាក្សី **ស៊ុំ ជា** ថាជាការឆ្លើយផ្អែកតែលើការនិយាយតៗគ្នា ឬជាពាក្យចចាមអារ៉ាមដែលគាត់បានឮពីកម្មាភិបាល **គឿន** តែម្ខាង ។ លើសពីនេះទៅទៀត ចៅក្រម **ហ្សង់ម៉ាក ឡាវែន៍ (**Jean Marc Lavergne) ព្រមជាមួយនឹងមេធាវីអន្តរជាតិរបស់លោក **នួន ជា** គឺលោក **ហ្សាស្ពើ ប៉ៅ** (Mr. Jasper Pauw) បានសួរសំណួរច្រំដែរមួយចំនួន ក្នុងបំណងឲ្យសាក្សី **ស៊ុំ ជា** ឆ្លើយបញ្ជាក់ឲ្យច្បាស់នូវចម្លើយជាច្រើនលើកច្រើនសាររបស់គាត់ ថាគ្មានជនស៊ីវិលណាម្នាក់នៅក្នុងស្ថានទូតបារាំង ។ ជាក់ស្តែងនៅពេលដែលមេធាវីអន្តរជាតិការពារក្តីរបស់ **អៀង សារី** គឺលោក **ម៉ៃខល កាណាវ៉ាស** (Michael Karnavas) ដល់វេនត្រូវសួរដេញដោល លោក **ស៊ុំ ជា** បានឆ្លើយម្តងទៀតថា ពុំមាននរណាម្នាក់នៅក្នុងស្ថានទូតបារាំងនោះទេចាប់តាំងពីពេល *"រំដោះ"* ភ្នំពេញបានបីថ្ងៃមកម្ល៉េះ ។[៧] មេធាវី **ប៉ៅ** មានបំណងស្នើសុំប្រើប្រាស់ឯកសារស្រាវជ្រាវរបស់លោក **ម៉ៃខល វីគើរី** (MichaelVickery) ដើម្បីតទល់នឹងចម្លើយរបស់លោក **ស៊ុំ ជា** ដែលថាបុគ្គលិកនៅមន្ទីរពេទ្យ*កាល់ម៉ែត* ត្រូវបានរត់ចោលជួរលែងបម្រើការងារក្នុងមន្ទីរពេទ្យទៀត ចំពេលដែលគាត់បានទៅដល់ទីនោះ ។ ទោះបីជាយ៉ាងណាក្តី ការស្នើសុំនេះមិនត្រូវបានអនុញ្ញាតដោយអង្គជំនុំជម្រះឡើយ ។

បន្ថែមពីនេះ សាក្សីបានពន្យល់តាំងពីខាងដើមមកម្ល៉េះ អំពីដែនសមត្ថកិច្ចរៀងៗខ្លួនរបស់កងទ័ព ដែលបានឈរជើងតាមទិសខុសៗគ្នាក្នុងទីក្រុងភ្នំពេញ ក៏ប៉ុន្តែមេធាវី **ប៉ៅ** បានដាក់បង្ហាញសេចក្តីថ្លែងការណ៍មួយចំនួនរបស់លោក **ហេង សំរិន** ជាអតីតមេបញ្ជាការរងកងពលប្រចាំការភូមិភាគបូព៌ា ដែលបានផ្តល់នូវសេចក្តីថ្លែងលើបញ្ហាតែមួយ តែចម្លើយខុសគ្នាជាមួយសាក្សីរូបនេះ ដូច្នេះហើយ ទើបមេធាវីមានបំណងចង់ប្រើប្រាស់សេចក្តីថ្លែងនេះដើម្បីសួរផ្ទៀញ់សាក្សី ។[៨] មតិយោបល់របស់លោក **ហេង សំរិន** បានអះអាងដោយមិនប្រែប្រួលថា កងទ័ពមកពីភូមិភាគបូព៌ា គឺមាន*"ចិត្តស្លូតបូត"* មានអាកប្បកិរិយាល្អ និងគោរពវិន័យបានល្អជាងកងទ័ពមកពីភូមិភាគដទៃទៀត ។ នេះជាការអះអាងផ្ទុយនឹងការបញ្ជាក់របស់សាក្សីដែលបានតាំងខ្លួនថា ជាអ្នកបានដឹងឮអំពីកងទ័ពមកពីភូមិភាគបូព៌ា មាន*"ចិត្ត*

*ឃោរឃៅជាទីបំផុត*" ។ មានចំណុចមិនស៊ីចង្វាក់គ្នាមួយផ្សេងទៀត គឺនៅពេលសាក្សីបានរ៉ាយរ៉ាប់ពីវិធីដែលគាត់បានស្តាប់ចម្រៀងស្នេហាជាតិតាមវិទ្យុជារៀងរាល់ថ្ងៃ ប៉ុន្តែគាត់ធ្លាប់បាននិយាយពីមុនថា គាត់មិនធ្លាប់មានវិទ្យុស្តាប់នូវការផ្សាយរបស់*រណសិរ្សរួបរួមជាតិកម្ពុជា (*FUNK) ទេ អំឡុងពេលដែលគាត់នៅភ្នំពេញ ។ មេធាវី **កាណាវ៉ាស** បានធ្វើការសន្និដ្ឋានទៅលើសក្ខីកម្មរបស់លោក **ស៊ុំ ជា** ថា *"ភាគច្រើននូវអ្វីដែលសាក្សីប្រាប់អង្គសវនាការនៅថ្ងៃនេះ គឺជាអ្វីដែលអ្នកដទៃបានប្រាប់គាត់ ក៏ប៉ុន្តែសាក្សីរូបនេះមិនទាំងមានវត្តមាន ឬបានឃើញផ្ទាល់ភ្នែកខ្លួនឯងនោះទេ*"។

ជាញយដងក្នុងពេលកំពុងផ្តល់សក្ខីកម្ម លោក **ស៊ុំ ជា** បានងាកទៅរកជំនួយពីមេធាវីប្រឹក្សាផ្ទាល់របស់គាត់មុនពេលឆ្លើយតបទៅនឹងសំណួរជាក់លាក់ផ្សេងៗ (សំណួរលំបាកៗ) ដែលនៅត្រង់ចំណុចនេះហើយ សូម្បីតែលោកប្រធានអង្គជំនុំជម្រះ **និល ណុន** ក៏បានធ្វើការក្រើនរម្លឹកដល់សាក្សីរូបនេះផងដែរថា មេធាវីប្រឹក្សារបស់គាត់អាចនឹងលូកដៃបានក្នុងករណីដែលសាក្សីមានការភ័យខ្លាចនឹងផ្តល់ចម្លើយទាំងឡាយណា ដែលអាចដាក់ពិរុទ្ធលើខ្លួនឯងតែប៉ុណ្ណោះ ។ ត្រង់ចំណុចនេះ វាអាចទៅរួចដែលសាក្សីទំនងជាមានការភ័យខ្លាចនឹងការឆ្លើយដាក់បន្ទុកលើខ្លួនឯង ឬអាចមានការបារម្ភនូវការជាប់ពាក់ព័ន្ធរបស់គាត់ជាមួយព្រឹត្តិការណ៍មួយចំនួនក្នុងរបបកម្ពុជាប្រជាធិបយ្យ ។

## ខ. សក្ខីកម្មអ្នកស្រី មុម សំអឿន

ពេញមួយថ្ងៃអង្គារនេះ កិច្ចដំណើរការនីតិវិធីស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី **មុម សំអឿន** ត្រូវបានចប់សព្វគ្រប់ ។[៩] ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បានផ្តល់សក្ខីកម្មពីបទពិសោធន៍របស់អ្នកស្រីក្នុងអំឡុងពេលជម្លៀសដោយបង្ខំទៅលើក្រុមគ្រួសាររបស់គាត់ឲ្យចាកចេញពីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ បន្ទាប់មកគាត់បានពិពណ៌នាពីស្ថានភាពជាច្រើននៅតាមបណ្តាខេត្ត ដែលក្រុមគ្រួសាររបស់គាត់ត្រូវបានបញ្ជូនទៅឲ្យរស់នៅនិងធ្វើការងារ ។ អ្នកស្រីក៏បានផ្តល់ព័ត៌មានលម្អិតជុំវិញពីការប្រព្រឹត្តលើប្រជាជន "*ថ្មី*" ដោយប្រជាជនមូលដ្ឋាននៅទីនោះ ។ ដើមបណ្តឹងរដ្ឋប្បវេណី ក៏បានរៀបរាប់ពីទំនាក់ទំនងកាលពីមុនជាមួយនឹងលោក **សាឡុត ស** ដែលមានរហស្សនាមថា **ប៉ុល ពត** និងលោក **អៀង សារី** ផងដែរ នៅពេលដែលពួកគាត់បានរៀនជាមួយគ្នានៅ*លីសេព្រះស៊ីសុវត្ថិ* (វិទ្យាល័យព្រះស៊ីសុវត្ថិ) ។ អ្នកស្រីបាននិយាយពីភាពស្រពេចស្រពិលដែលគាត់នៅតែមានរហូតដល់ថ្ងៃនេះពីការបាត់ខ្លួនប្តី និងកូនៗទាំងប្រាំមួយនាក់របស់គាត់ បើទោះណាជាអ្នកស្រីបានសន្និដ្ឋានថា ពួកគេបានបាត់បង់ជីវិតអស់ហើយ។

### *ខ.១. ការជម្លៀសចេញពីភ្នំពេញ*

អ្នកស្រី **មុម សំអឿន** ជាកូនស្រីរបស់អតីតពេទ្យហ្លួងក្នុងរាជវាំងម្នាក់ ។ អ្នកស្រីបានកើតក្នុងឆ្នាំ១៩២៧ ក្នុងរាជធានីភ្នំពេញ។[១០] ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បានទទួលការបណ្តុះបណ្តាលឲ្យក្លាយទៅជាសាស្ត្រាចារ្យភាសាបារាំងដែលបានបង្រៀននៅក្នុង*វិទ្យាល័យកំពត* រហូតដល់ឆ្នាំ១៩៧០ ទើបគាត់បានប្តូរមកធ្វើការខាងផ្នែកនិពន្ធសៀវភៅវិញនៅក្នុង*ក្រសួងអប់រំ* ដើម្បីបានមករស់នៅជិតប្តីនៅឯទីក្រុងភ្នំពេញ ។[១១] នៅព្រឹកព្រលឹមថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គាត់បានឮសម្លេងរថក្រោះបើកបរក្បែរផ្ទះរបស់គាត់ដែលមានទីតាំងនៅភាគខាងជើងវិមានឯករាជ្យ។[១២] អ្នកស្រីត្រូវបានទ័ពខ្មែរក្រហមភ្ជង់កាំភ្លើងពីខាងក្រោយខ្នង នៅខណៈពេលដែលគាត់បានទៅចាក់សោទ្វារផ្ទះ ដើម្បីរក្សាសុវត្ថិភាពគ្រួសារ និងប្រមូលយកវត្ថុមានតម្លៃមួយចំនួនមកតាមខ្លួន ក្នុងករណីចាំបាច់ត្រូវភៀសខ្លួនចេញពីផ្ទះ ។ នៅពេលនោះ អ្នកស្រីអាចកត់សម្គាល់ថាជាទាហានខ្មែរក្រហមបាន ដោយសារពួកគេបានស្លៀកឯកសណ្ឋានឈុតពណ៌

ខ្មៅ និងមានចងក្រមាពណ៌ក្រហមនៅនឹងក ។ នៅពេលដែលទាហានទាំងនេះកំពុងភ្ជង់កាំភ្លើងដាក់អ្នកស្រី និងបានចោទគាត់ថាជាមនុស្ស*"គិតតែពីខ្លួនឯងគ្មានគិតជួយអ្វីដល់បដិវត្តន៍សោះ"* ចំណែកឯកូនៗរបស់អ្នកស្រី **មុម សំអឿន** បានស្រែកយំយ៉ាងខ្លាំង។ ពួកទាហានទាំងនោះ បានកញ្ឆក់យកវ៉ែនតារបស់អ្នកស្រីគ្រវែងចោល ដោយចាត់ទុកថា (របស់លម្អរ) វាជាការប្រឆាំងនឹងបដិវត្តន៍ ដោយមិនគិតថាអ្នកស្រីមើលឃើញ ឬមិនឃើញក៏ដោយ នៅពេលគ្មានវ៉ែនតានោះ។ [១៣] ទាហានខ្មែរក្រហមបានបញ្ជាឲ្យគាត់នាំក្រុមគ្រួសារទាំងអស់ចាកចេញពីទីក្រុង ដោយប្រាប់មូលហេតុថាពួកអាមេរិកនឹងទម្លាក់គ្រាប់បែកនាពេលឆាប់ៗ ក៏ប៉ុន្តែពួកទាហានទាំងនោះមិនអនុញ្ញាតឲ្យគាត់ខ្ចប់យកឥវ៉ាន់អ្វីច្រើនទៅជាមួយឡើយដោយពួកគេបានប្រាប់ថា ទៅតែប៉ុន្មានថ្ងៃក្រោយមក ក្រុមគ្រួសារអ្នកស្រីអាចវិលត្រឡប់មកផ្ទះវិញបាន ។ ទាហានខ្មែរក្រហម បានរឹបអូសយកសោរទ្បានក្រុមហ៊ុនប្តីរបស់អ្នកស្រី*ម៉ាកឡង់រ៉ូវ៉េ* និងទ្បានថ្មីរបស់គាត់មួយទៀត ។ ចំណែកប្តីរបស់គាត់វិញ បាននាំកូនស្រីពៅទៅជាមួយ និងយកអាហារមួយចំនួនទុកក្នុងទ្បានមួយផ្សេងទៀតដែលជាប្រភេទ*វ៉ុលវ៉ាហ្គេនតូច* ប៉ុន្តែប្តីគាត់ត្រូវបានពួកទាហានខ្មែរក្រហមបង្ខំឲ្យចាកចេញទៅផ្លូវផ្សេងពីគ្នាខណៈដែលអ្នកស្រី និងកូនៗដែលនៅជាមួយគាត់ត្រូវបង្ខំឲ្យដើរដោយថ្មើរជើង ។

អ្នកស្រី **មុម សំអឿន** បានពន្យល់ថា នៅទិសដែលអ្នកស្រីត្រូវទៅ គឺមានមនុស្សអ៊ូអរច្រើនណាស់ ហើយពួកទាហានខ្មែរក្រហមបានប្រើម៉ៃក្រូបំពងសម្លេងស្រែកប្រកាសឲ្យប្រជាជនចាកចេញពីទីក្រុងជាបន្ទាន់ និងគំរាមភ្ជង់កាំភ្លើងឲ្យចេះដំណើរឲ្យលឿន។ ទាហានខ្មែរក្រហមទាំងនោះ មិនបានផ្តល់មធ្យោបាយសម្រាប់ធ្វើដំណើរណាមួយ ដូចជា អាហារ ថ្នាំពេទ្យ ឬទឹកផឹក ដល់ពួកគាត់ឡើយ ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បាននិយាយបញ្ជាក់ថា *"គ្មានគិតពីអ្នកឈឺ មនុស្សចាស់អី អ្នកព្យួរសេរ៉ូមហ្នឹង ខ្លះកាន់សេរ៉ូមខ្លួនឯង ដើរតេតេះ តតះ ស៊ីក៏ស៊ីទៅ ។ វាធ្វើដូចវាមិនមែនខ្មែរអីចឹង វាធ្វើបាបប្រជាជន"* ។ អ្នកស្រីបានពិពណ៌នាជាថ្មីនូវទិដ្ឋភាពគួរឲ្យភ័យខ្លាចនៅតាមដងផ្លូវដែលពោរពេញដោយសាកសពមនុស្សដាច់ក្បាល ។ សាកសពទាំងនោះ មានខ្លះពាក់ឯកសណ្ឋានស៊ីវិល ឯខ្លះទៀតពាក់ឯកសណ្ឋានអតីតយោធា **លន់ នល់** ។ ដើមបណ្តឹងរដ្ឋប្បវេណី ក៏បានឃើញមានមនុស្សស្លាប់ដោយសារតែការស្រេកឃ្លានអស់កម្លាំង និងកង្វះជាតិទឹក បូករួមទាំងស្ត្រីមានផ្ទៃពោះកំពុងសម្រាលកូន និងរលូតកូនតាមដងផ្លូវដែលអ្នកស្រីបានឆ្លងកាត់ផងដែរ ។ ទោះបីជាយោធាខ្មែរក្រហមបន្តគំរាមឲ្យប្រជាជានធ្វើការជម្លៀសចេញឲ្យលឿនយ៉ាងណាក៏ដោយ អ្នកស្រី **មុម សំអឿន** មិនដែលបានឮទាហានទាំងនោះនិយាយថាតើថ្នាក់លើណាមួយជាអ្នកដាក់បញ្ជាឲ្យប្រជាជនចេញពីទីក្រុងភ្នំពេញឡើយ។

### *ខ.២. បទពិសោធន៍ដំបូងនៅតាមបណ្តាខេត្តៈ ពីភ្នំពេញទៅស្រុកសំរោង*

អ្នកស្រី **មុម សំអឿន** បានមកជួបជុំជាមួយប្តីរបស់អ្នកស្រីដោយជិះរថយន្ត*វ៉ុលវ៉ាហ្គេន* នៅមុំស្ពាន*ព្រះមុន្នីវង្ស (ស្ពានក្បាលថ្នល់បច្ចុប្បន្ន)* ហើយពួកគាត់មានបំណងចង់ទៅខេត្ត*ស្វាយរៀង* ដែលជាស្រុកកំណើតប្តីរបស់អ្នកស្រី ។ ទោះបីជាយ៉ាងនេះក្តី ស្ពានដែលឆ្លងទៅកាន់ខេត្ត*ស្វាយរៀង* ត្រូវបានបិទដោយខ្មែរក្រហម ដូច្នេះហើយ ពួកគាត់បានសម្រាកមួយយប់នៅក្នុងវត្ត*សំរោង* ។ នៅទីនោះ ពួកគាត់បាននាំគ្នាស្នាក់នៅយ៉ាងស្ងប់ស្ងាត់ពេញមួយយប់ដើម្បីគេចវេសពីការភ័យខ្លាចស្នូរសម្លេងកាំភ្លើង ពីការឃើញសាកសពមនុស្សស្លាប់ និងក្លិនផ្សេងឆ្អួលពេញក្រុង ។ នៅព្រឹកបន្ទាប់មក ពួកគាត់ត្រូវបានគេប្រាប់ឲ្យចាកចេញពីទីនោះ ហើយបានបន្តដំណើរតាមបណ្តោយផ្លូវមាត់ទន្លេដោយឆ្លងកាត់ភូមិ*ស្វាយរលំ* ជាទីកន្លែងដែលពួកគាត់បានផ្អាកការធ្វើដំណើរក្នុងរយៈពេលខ្លី ដើម្បីស្វែងរកគ្រឿងផ្សំផ្សេងៗទុកសម្រាប់ធ្វើម្ហូបអាហារ ពីព្រោះតែមិនបានទទួលរបបអាហារផ្គត់ផ្គង់អ្វីឡើយ ។ នៅតាមផ្លូវក្បែរវត្តមួយ

យោធាខ្មែរក្រហមបានឃាត់ឡាន និងរឹបអូសយកឡាននោះពីពួកគាត់យកទៅបើក ក៏ប៉ុន្តែដោយសារពួកគេមិនចេះបើកបរ ឡានក៏ត្រូវបានខូចខ្ទេច និងត្រូវបោះបង់ចោលភ្លាមៗដែរ។

ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ប្រាប់ថា ក្នុងអំឡុងពេលធ្វើដំណើរ ពួកគាត់*"ស្ថិតនៅក្រោមការឃ្លាំមើលយ៉ាងតឹងរឹង"* ពីយោធាខ្មែរក្រហម ដែលចេះតែឈ្លេចសួរនាំអ្នកស្រី និងប្តីអ្នកស្រី អំពីមុខងាររបស់ពួកគាត់ ។ អ្នកស្រីបានកុហក និងមិនប្រាប់ទាហានទាំងនោះថាអ្នកស្រីជាសាស្ត្រាចារ្យភាសាបារាំងនោះទេ ដោយនិយាយថាអ្នកស្រីគ្រាន់តែជាមេផ្ទះម្នាក់តែប៉ុណ្ណោះ។ ឆ្លើយតបទៅនឹងការសួរដេញដោលនូវសំណួរជាក់លាក់លើចំណុចនេះពីសំណាក់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី **បេនី យេ** (Beini Ye) អ្នកស្រី **មុម សំអឿន** បានឆ្លើយថា *"ខ្ញុំមិនហ៊ានប្រាប់គេទេ ខ្លាចគេយកទៅសម្លាប់ហ្នឹងណា៎ ។ ព្រោះគេដៀល គ្រាន់តែកូនខ្ញុំមិនចេះធ្វើអី ក៏គេដៀលខ្ញុំសក្តិភូមិទៅហើយ ចុះទម្រាំខ្ញុំប្រាប់ថាខ្ញុំជាអ្នកធ្វើការទៀតហ្នឹង វាកាន់តែធ្ងន់ទៅទៀតហើយ"* ។ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានពន្យល់បន្ថែមថា អ្នកស្រីបានដឹងថា ខ្មែរក្រហមមិនសូវចូលចិត្តអ្នកចេះដឹងទេ ម៉្លោះហើយ អ្នកស្រីបានធ្វើពុត*ជា "មនុស្សល្ងង់"* ។

ដើមបណ្តឹងរដ្ឋប្បវេណី និងគ្រួសាររបស់គាត់ បានបន្តដំណើរតាមបណ្តោយមាត់ទន្លេបានប្រមាណ ៤០ គីឡូម៉ែត្រ មកដល់ឃុំ*សំរោង* ទើបពួកគាត់សម្រាក។ នៅពេលនោះ កូនស្រីរបស់អ្នកស្រីម្នាក់មានជម្ងឺ *"ដំបៅក្នុងត្រចៀក"* ហើយម្នាក់ទៀតបានសន្លប់ដោយសារហេវហត់ពីការធ្វើដំណើរដ៏វែងឆ្ងាយ។ ពួកគាត់បានស្នាក់នៅពីរយប់នៅក្នុងផ្ទះរបស់អ្នកស្រុកម្នាក់ឈ្មោះ **កុង នាង** ដែលមានចិត្តអាណិតអាសូរដល់ក្រុមគ្រួសាររបស់អ្នកស្រីដែលមានកូនច្រើនសុទ្ធតែបាក់កម្លាំង គាត់បានលួចផ្តល់ម្ហូបអាហារ ក៏ដូចជាកន្លែងស្នាក់នៅដល់ក្រុមគ្រួសាររបស់អ្នកស្រីទៀតផង។ នៅថ្ងៃទីពីរក្នុងឃុំ*សំរោង* អ្នកស្រីបានឃើញកប៉ាល់ដឹកប្រជាជនជាច្រើនឆ្លងកាត់ទន្លេ ហើយក៏ឃើញកប៉ាល់ទាំងនោះវិលត្រឡប់មកវិញដោយបន្សល់ទុកនៅរបស់របរប្រើប្រាស់មកជាមួយដែរ ។ គ្រួសាររបស់អ្នកស្រីបានសន្និដ្ឋានថា ប្រជាជនទាំងនោះត្រូវបានគេសម្លាប់ចោលទាំងអស់ ។ ដើមបណ្តឹងរដ្ឋប្បវេណី ក៏បានផ្តល់សក្ខីកម្មថាអ្នកស្រីមិនដែលបានទទួលសេចក្តីណែនាំឲ្យវិលត្រឡប់ទៅភ្នំពេញវិញនោះទេ ថ្វីបើជាពួកគាត់មិនបានឮពីការទម្លាក់គ្រាប់បែកក្តី។

នៅស្រុក*សំរោង* ទាហានខ្មែរក្រហមបានឲ្យប្តី និងកូនប្រុសៗរបស់អ្នកស្រីទាំងអស់ដើរកាត់ស្មៅ និងចិញ្ចឹមគោមួយហ្វូង ។ កូនប្រុសទីពីររបស់អ្នកស្រី មិនធ្លាប់ធ្វើការងារនេះពីមុនមកទេ ម៉្លោះហើយបានជាត្រូវគោជាន់លើមុខបាក់ឆ្អឹងថ្គាម និងរងរបួសជាច្រើនកន្លែងទៀតផង ។ ដោយឃើញដូចនេះ ពួកទាហានបានវាយអ្នកស្រី **មុម សំអឿន** ដោយស្តីបន្ទោសអ្នកស្រីថា ចិញ្ចឹមកូនថ្នមតាមតែពួកសក្តិភូមិ និងអត់ចេះប្រើកូនឲ្យធ្វើការងារអ្វីសោះ ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានពន្យល់ថា ពាក្យ*"ពួកសក្តិភូមិ"* ឬ*"ប្រជាជន១៧មេសា"* សំដៅលើអតីតអ្នកមានអំណាច និងអ្នកដែលមានទ្រព្យសម្បត្តិច្រើន ចំណែកឯពាក្យប្រជាជន *"មូលដ្ឋាន"* សំដៅលើកសិករក្រីក្រ ដែលចេះតែមើលសត្វគោក្របី និងធ្វើស្រែចម្ការ ។ អ្នកស្រី **មុម សំអឿន** បានគូសបញ្ជាក់ត្រង់ចំណុចនេះថា ចាប់តាំងពីការជម្លៀសពីភ្នំពេញរហូតមកនេះ អ្នកស្រីបានជួបប្រជាជនមូលដ្ឋានដែលមានទាំងអ្នកល្អ និងអ្នកអាក្រក់ ។ ចំពោះអ្នកចិត្តអាក្រក់គេបានចាត់ទុកអ្នកស្រីជាប្រជាជនថ្មី និងចោទអ្នកស្រីថាជា *"ពួកឆ្លៀតឱកាស ឬពួកអ្នកចាំដណ្តើមម្ហូបអាហារពីពួកគេ"* ។ ដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយតបទៅពួកគេវិញថា *"មិនមែនជាកំហុសរបស់ខ្ញុំនោះទេដែលមកនៅទីនេះ ។ តាមពិតជាកំហុសរបស់អ្នកដែលនាំក្រុមគ្រួសាររបស់ខ្ញុំមកទេតើ"* ។ អ្នកស្រីក៏បានជួបប្រជាជន *"មូលដ្ឋាន"* ដែលមានសន្តានចិត្តល្អចំពោះអ្នកស្រី និងបានជួយផ្គត់ផ្គង់ម្ហូបអាហារបរិភោគទៀតផង ។

## ខ.៣. *ការជម្លៀសបន្ត៖ ពីស្រុកសំរោងទៅព្រៃកគយ ហើយទៅកាន់កោះខ្សាច់ជន្លា*

បន្ទាប់ពីមួយសប្តាហ៍នៅស្រុក*សំរោង* ក្រោយមក គ្រួសាររបស់អ្នកស្រីត្រូវបានបញ្ជាឲ្យផ្លាស់ទៅកាន់ស្រុក*ស្អាង* ឃុំ*ព្រៃកគយ* ខេត្ត*កណ្តាល* ចម្ងាយប្រមាណពី ១០ ទៅ ២០ គីឡូម៉ែត្រ ។ នៅទីនោះ អ្នកស្រី **មុម សំអឿន** បានចូលរួមប្រជុំជាច្រើនដងជាមួយមេឃុំ ដែលតែងតែបង្ខំឲ្យប្រជាជនធ្វើការជាទម្ងន់ និងធ្វើបាបប្រជាជន“*ថ្មី*”ណាដែលមិនធ្លាប់រស់នៅស្រុកស្រែពីមុនមក ។ នៅពេលនោះ អ្នកស្រីបានកើតជំងឺហើមពេញខ្លួន ប្រហែលជាមកពីការបរិភោគអាហារមិនមានជីវជាតិគ្រប់គ្រាន់ ។ អ្នកស្រីត្រូវបានគេជៀលថា “*ប្រហែលឆ្លងរោគពីប្តី (សើស្បែក) ដោយសារដើរមានស្រីញីច្រើន*” ។ នៅឯ*ព្រៃកគយ* អ្នកស្រី **មុម សំអឿន** បាននៅបែកពីប្តី និងកូនៗទាំងអស់របស់គាត់ លើកលែងតែកូនម្នាក់ដែលកើតជម្ងឺហឺត ។ ចំណែកប្តីអ្នកស្រី ត្រូវបានគេបញ្ជាឲ្យទៅមើលគោនៅម្តុំខាងត្បូង*ព្រៃកគយ* ។ ដោយឡែកកូនច្បងទាំងអស់របស់អ្នកស្រី ត្រូវបានគេបញ្ជូនទៅសង់ទំនប់ទឹក និងលើកទំនប់ស្រែ ហើយកូនៗផ្សេងទៀត គេឲ្យទៅលើកផ្លូវនៅឯ*ទួលក្រសាំង* ។ នៅសល់តែកូនពៅដែលត្រូវគេយកទៅនៅជាមួយកូនរបស់អ្នកមូលដ្ឋានក្នុងកងកុមារនៅវត្ត*បឹងឈូក* ចម្ងាយប្រមាណជាង ២០គីឡូម៉ែត្រពីផ្ទះរបស់អ្នកស្រី ។

មានម្តងនោះ នៅពេលដែលគេបង្ខំឲ្យទៅមើលកុន អ្នកស្រី **មុម សំអឿន** ត្រូវបានអ្នកចូលរួមមើលជាមួយគ្នាប្រាប់ឲ្យស្គាល់លោក **ប៉ុល ពត** ។ នៅពេលនោះ អ្នកស្រី បានចំណាំលោក **ប៉ុល ពត** ថាជា **សាឡុត ស** ដែលធ្លាប់ស្គាល់កាលនៅរៀនជាមួយគ្នានៅឯ*លីសេស៊ីសុវត្ថិ* ក្នុងក្រុងភ្នំពេញ។ អ្នកស្រីបានបញ្ជាក់ឲ្យដឹងផងដែរថា កាលនៅរៀនសាលាមធ្យមសិក្សា (អនុវិទ្យាល័យ) អ្នកស្រីធ្លាប់បានស្គាល់លោក **អៀង សារី** ទោះបីជាមិនបានរៀនក្នុងថ្នាក់ជាមួយគ្នាក៏ដោយ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ក៏ធ្លាប់ស្គាល់អ្នកស្រី **ខៀវ ប៉ុណ្ណារី** ដែលជាប្រពន្ធរបស់លោក **សាឡុត ស** និងធ្លាប់រៀនជាមួយ **អៀង ធីរ៉ាត់** ដែលត្រូវជាបងស្រីបង្កើតរបស់ **អៀង ធីរិទ្ធ**។ អ្នកស្រីបានគូសបញ្ជាក់ថា “*លោក **អៀង សារី** និង **សាឡុត ស** រៀននៅថ្នាក់ផ្សេងគ្នា ហើយខ្ញុំរៀននៅថ្នាក់ផ្សេងមួយទៀត តែខ្ញុំបានស្គាល់លោក **អៀង សារី** យ៉ាងច្បាស់ ។ ខ្ញុំក៏ស្គាល់លោក **សាឡុត ស** ច្បាស់ដែរ*” ។ ក៏ប៉ុន្តែអ្នកស្រីបានប្រាប់ឲ្យដឹងថា នៅពេលនោះអ្នកស្រីមិនបានដឹងពីផ្នត់គំនិតនយោបាយអ្វីរបស់លោក **សាឡុត ស** ឡើយ ។

នៅក្នុងឆ្នាំ១៩៧៧ ទាំងស្វាមី កូនស្រីប្រាំនាក់ និងកូនប្រុសម្នាក់របស់អ្នកស្រី **មុម សំអឿន** ត្រូវបានគេដឹកបញ្ជូនតាមឡានមួយយកចេញទៅ ។ នៅពេលនោះ មេឃុំបានប្រាប់អ្នកស្រីថាពួកគាត់នឹងវិលត្រឡប់មកជួបជុំអ្នកស្រីឆាប់ៗនេះ ។ អ្នកស្រីត្រូវបានគេបញ្ជូនទៅឃុំនៅ*កោះខ្សាច់ជន្លា* (ជាទីកន្លែងដែលអ្នកស្រីពិពណ៌នាថា ជាគុកឥតជញ្ជាំង) ឲ្យនៅជាមួយប្រពន្ធរបស់អតីតទាហានខ្មែរសាធារណរដ្ឋ ។ នៅទីនោះ ពួកគាត់មិនត្រូវបានអនុញ្ញាតឲ្យនិយាយទាក់ទងគ្នាឡើយ ហើយនៅពេលមួយនោះផងដែរ ដើមបណ្តឹងរដ្ឋប្បវេណី បាននិយាយរៀបរាប់ពីការកាប់សម្លាប់ទៅលើស្ត្រីម្នាក់ ដោយសារតែគាត់បានលួចបេះផ្លែឈើមកបរិភោគ ។ ដល់ត្រង់ចំណុចនេះ អ្នកស្រីបាននិយាយថា៖ “*ខ្ញុំទ្រាំទ្រតែចិត្តណាស់ មិនដឹងជាដល់វេនខ្ញុំពេលណានោះទេ*” ។ នៅពេលដែលកូនប្រាំនាក់ គឺកូនស្រីពៅ និងកូនប្រុសច្បងបួននាក់ បានទៅរកអ្នកស្រីនៅ*គុកកោះខ្សាច់ជន្លា* ក្រោយពេលរបបខ្មែរក្រហមដួលរំលំ គឺពេលនោះហើយដែលអ្នកស្រីដឹងច្បាស់ថា ប្តី និងកូនដទៃទៀតរបស់គាត់“*ត្រូវបានគេយកទៅសម្លាប់*” ។

## ខ.៤. សេចក្តីរៀបរាប់ពីទុក្ខសោកវេទនា ឥរិយាបទ និងភាពជឿជាក់របស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្នុងអំឡុងពេលនៃសេចក្តីថ្លែងរៀបរាប់ពីទុក្ខសោកវេទនា អ្នកស្រី **មុម សំអឿន** បាននិយាយសំដៅលើព្រឹត្តិការណ៍ និងបទពិសោធន៍ជាច្រើន ដូចដែលអ្នកស្រីបានឆ្លើយរៀបរាប់ប្រាប់ភាគីទាំងអស់អំឡុងពេលនៃការសួរដេញដោល ប៉ុន្តែអ្នកស្រីក៏បានរៀបរាប់ទៅលើបញ្ហាជាក់លាក់ពីរ ឬបីបន្ថែមទៀត ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ក៏បានបញ្ជាក់សាជាថ្មីម្តងទៀតថា បច្ចុប្បន្នអ្នកស្រីរស់នៅ អាស្រ័យលើថ្នាំពេទ្យសម្រាប់ព្យាបាលជម្ងឺប្រចាំកាយដែលអ្នកស្រីបានទទួលរងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ភ្នែករបស់អ្នកស្រី មានសភាពកាន់តែងងឹតជាងមុនដោយពុំបានពាក់វ៉ែនតាពេញមួយរបបនេះ ហើយអ្នកស្រីមិនអាចទទួលទានដំណេកបានសុខស្រួលដូចធម្មតានោះទេ តែងតែញ័រខ្លួនជាប្រចាំ ដោយសារតែការនឹកឃើញនូវរឿងរ៉ាវជូរចត់ពីអតីតកាល ។ បច្ចុប្បន្ននេះ អ្នកស្រីនៅតែមានជម្ងឺហើមជើងបណ្តាលមកពីការប្រព្រឹត្តរបស់ពួកខ្មែរក្រហមមកលើគាត់ ។ បច្ច័យនៃបទពិសោធន៍របស់អ្នកស្រីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានក្លាយជាការចាប់អារម្មណ៍យ៉ាងសម្បើមទៅលើបញ្ហាសុខភាពផ្លូវចិត្ត ពីព្រោះថាៈ ដើមបណ្តឹងរដ្ឋប្បវេណីនៅតែគិតពីភាពអាចទៅរួច (គិតមិនអស់មិនហើយ) ជុំវិញការស្លាប់របស់កូនស្រីច្បងទាំងប្រាំរបស់អ្នកស្រីមិនដឹងថាដោយសារការរំលោភសេពសន្ថវៈមុននឹងត្រូវពួកខ្មែរក្រហមសម្លាប់ ឬដោយប្រការណា ហើយនិងរឿងដែលអ្នកស្រីនៅនឹកឃើញជាប្រចាំ គឺរូបភាពនៃស្ត្រីម្នាក់ដែលត្រូវគេសម្លាប់យ៉ាងព្រៃផ្សៃ ពីព្រោះតែលួចផ្លែឈើមួយផ្លែមកបរិភោគ ហើយអ្នកស្រីក៏នៅតែនឹកទន្ទឹងរង់ចាំមើលផ្លូវប្តីខ្លួនថាថ្ងៃណាមួយគាត់នឹងវិលត្រឡប់មករកអ្នកស្រីវិញ ។

ដើមបណ្តឹងរដ្ឋប្បវេណី ក៏បានពន្យល់ពីស្ថានភាពក្រោយការដួលរំលំនៃរបបកម្ពុជាប្រជាធិបតេយ្យថា អ្នកស្រីនៅសល់តែបាតដៃទទេ ហើយក្រោយពេលចាកចេញពីទីឃុំឃាំងអ្នកស្រីបានលួចទម្លាក់អាយុ ដើម្បីអាចបន្តធ្វើការរាជការបាន និងរកលុយចិញ្ចឹមកូនៗអ្នកស្រីដែលនៅសល់ឲ្យបានរៀនសូត្រ ។ អ្នកស្រី **មុម សំអឿន** បានបញ្ចប់សេចក្តីថ្លែងការណ៍របស់គាត់ជាមួយនឹងអំណរគុណលាយលំនឹងអារម្មណ៍ឈឺចាប់ខ្លោចផ្សា ហើយក៏បានសម្តែងនូវការដឹងគុណចំពោះកូនៗអ្នកស្រី ក៏ដូចជាប្រជាជនមូលដ្ឋានចិត្តល្អមួយចំនួនដែលឧស្សាហ៍មកសួរសុខទុក្ខអ្នកស្រី ។ អ្នកស្រីបានថ្លែងថា ដោយសារតែអ្នកទាំងអស់នេះ បានជួយលួងលោមអ្នកស្រីឲ្យបន្តរស់នៅ និងមានអារម្មណ៍ធូរស្បើយប្រឹងប្រែងតស៊ូក្នុងជីវិតតទៅមុខទៀត។

ភាគច្រើន ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ចម្លើយតបភ្លាមៗ និងចំៗទៅនឹងសំណួរដេញដោល ។ អ្នកស្រីមិនមានបញ្ហាចំពោះការយល់នូវសំណួរដែលត្រូវសួរទៅលើអ្នកស្រីនោះទេ សូម្បីតែការសួរសំណួរបកចុះបកឡើង ក៏ដូចជាការសុំអ្នកស្រីជួយបញ្ជាក់បន្ថែមពីឃ្លាប្រយោគខ្លះៗពីសំណាក់មេធាវី **សុន អារុណ** ក៏អ្នកស្រីមិនមានបញ្ហាក្នុងការឆ្លើយតបដែរ ។ អ្នកស្រី **មុម សំអឿន** ជាប្រជាពលរដ្ឋមានវ័យចំណាស់ម្នាក់ក្នុងចំណោមជនវ័យចំណាស់ដទៃទៀតដែលបានមកផ្តល់សក្ខីកម្មក្នុងសវនាការ អ្នកស្រីបានផ្តល់នូវព័ត៌មានពិស្តារមួយចំនួនគួរឲ្យកត់សម្គាល់ និងបានបង្ហាញពីលទ្ធភាពយ៉ាងមាំទាំក្នុងការរៀបរាប់រឿងរ៉ាវអតីតកាលពីអ្វីដែលអ្នកស្រីធ្លាប់ឆ្លងកាត់ ឬបានឃើញផ្ទាល់ភ្នែកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

*ជំពូកទី៣ ៖* **បញ្ហាផ្នែកច្បាប់ និងនីតិវិធី**

## ក. ការសួរដេញដោលទៅលើនីតិវិធីធ្វើសម្ភាសន៍របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត និងភាពអាចទុកចិត្តបានរបស់សាក្សី

ជាថ្មីម្តងទៀត ក្រុមមេធាវីការពារក្តី បានសួរដេញដោលពីនីតិវិធីធ្វើបទសម្ភាសន៍របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ភាពអាចទុកចិត្តបានរបស់សាក្សី និងប្រភពនៃការយល់ដឹងរបស់សាក្សី ។ មេធាវី **កាណាវាស** បានកត់សម្គាល់ថា លោក **ស៊ុំ ជា** បានផ្តល់សក្ខីកម្មតាំងពីដំបូងទីយ៉ាងដូច្នេះថា ខ្លួនធ្លាប់បានផ្តល់បទសម្ភាសន៍ចំនួនពីរលើកជាមួយតំណាងការិយាល័យសហចៅក្រមស៊ើបអង្កេត ។ ទោះជាយ៉ាងនេះក្តី មានបទសម្ភាសន៍តែមួយប៉ុណ្ណោះដែលបានធ្វើកំណត់ហេតុ ហើយកំណត់ហេតុនេះទៀតសោត ក៏មិនបានធ្វើឲ្យគ្រប់ជ្រុងជ្រោយទាំងអស់នោះឡើយ ។ មេធាវី **កាណាវាស** បានគូសបញ្ជាក់ដោយចាត់ទុកប្រភពនៃការយល់ដឹង និងសក្ខីកម្មទាំងអស់របស់លោក **ស៊ុំ ជា** ក្នុងពេលធ្វើបទសម្ភាសន៍ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេតថាមានវិមតិសង្ស័យ ។ ជុំវិញការផ្តល់សក្ខីកម្មរបស់គាត់ ដោយរាប់បញ្ចូលនូវបញ្ហាដទៃទៀតមានជាអាទិ៍ ការដឹងឮរឿងរ៉ាវតែតាមការនិយាយតៗគ្នា និងភាពដែលអាចទៅរួចនៃការផ្តល់នូវអង្គហេតុមិនជាក់លាក់ក្នុងសក្ខីកម្ម( *សូមមើលជំពូក២ ក.៦*) ដូច្នេះ លទ្ធភាពនៃភាពមិនប្រក្រតីក្នុងការរៀបចំដំណើរការធ្វើបទសម្ភាសន៍រវាងសាក្សីជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត បានបង្កើតជាវិមតិសង្ស័យលើសក្ខីកម្មរបស់គាត់។

អនុលោមតាមវិធាន ៧៦(៧) បានបញ្ជាក់ថា រាល់វិវាទកម្មនៃនីតិវិធីទាំងអស់ដែលពាក់ព័ន្ធនឹងកិច្ចការរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រូវតែលើកឡើងនៅអំឡុងពេលនៃដំណាក់កាលមុនសវនាការ ។[១៤] ទោះជាយ៉ាងណាក៏ដោយ ករណីនេះ ភាគីក៏មិនអាចដឹងបានទេថា វាមានភាពមិនច្បាស់លាស់អ្វីខ្លះទាក់ទងនឹងរបៀបធ្វើកំណត់ហេតុ និងសកម្មភាពផ្សេងៗរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត រហូតទាល់តែមានការបង្ហាញខ្លួនសាក្សីនៅចំពោះមុខតុលាការ ។ ចំពោះសាក្សីបានអះអាងតាំងពីចាប់ផ្តើមផ្តល់សក្ខីកម្មមកម្ល៉េះថា គាត់ពិតជាបានធ្វើបទសម្ភាសន៍ចំនួនពីរលើកជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត ។ មុននឹងការផ្តល់សក្ខីកម្មរបស់សាក្សីរូបនេះ ភាគីបានដឹងត្រឹមតែថាមានបទសម្ភាសន៍ដែលបានធ្វើកំណត់ហេតុមួយតែប៉ុណ្ណោះ ។ វាជាការធ្វេសប្រហែសដ៏គួរឲ្យកត់សម្គាល់មួយ ដូចនេះហើយវាជាការសំខាន់ណាស់ដែលមេធាវី **កាណាវាស** បានតទល់សាក្សីជាមួយនឹងភាពលម្អៀងនេះ ។

វិធានផ្ទៃក្នុងនៃអ.វ.ត.ក ណែនាំពីនីតិវិធីនៃការធ្វើកំណត់ហេតុបទសម្ភាសន៍ជាមួយសាក្សីដល់សហចៅក្រមស៊ើបអង្កេត ។ យោងទៅតាមវិធាន ៥៥(៧) បុគ្គលិកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រូវតែធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សររាល់ពេលធ្វើសម្ភាសន៍ជាមួយសាក្សី ។[១៥] ចំណែកឯវិធាន ២៥(២) វិញថ្លែងថា ៖

> *ការសួរយកចម្លើយអាចត្រូវបានធ្វើឡើងដោយមិនចាំបាច់មានការថតសម្លេង ឬថតជារូបភាពនៅពេលណាដែលមានកាលៈទេសៈរារាំងចំពោះការថតនេះ។ ក្នុងករណីនេះ មូលហេតុដែលមិនអាចធ្វើការថតបានក្នុងពេលសួរចម្លើយ ត្រូវចុះក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ...។ ចម្លើយទាំងនេះ ត្រូវដាក់បញ្ចូលទៅក្នុងកំណត់ហេតុសួរចម្លើយ។*[១៦]

កាលពីថ្ងៃទី២ ខែវិច្ឆិកា ក្រុមការពារក្តីរបស់លោក **អៀង សារី** បានដាក់សំណើជូនអង្គជំនុំជម្រះសាលាដំបូងសុំឲ្យមានសវនាការជាសាធារណៈលើបញ្ហានេះ ។[១៧] អនុលោមតាមវិធាន ៩៣ និងវិធាន ២១[១៨] លោក **អៀង សារី** តាមរយៈក្រុមមេធាវីរបស់គាត់ បានស្នើទៅកាន់អង្គជំនុំជម្រះសាលាដំបូងឲ្យប្រើអំណាចស៊ើបអង្កេតរបស់ខ្លួនដើម្បីបើកសវនាការសាធារណៈ ដើម្បីស្តាប់សក្ខីកម្មរបស់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹងដំណើរការនីតិវិធីធ្វើបទសម្ភាសន៍ដែលគ្មានកំណត់ហេតុ *"ដើម្បីកំណត់ឲ្យជាក់លាក់ ប្រសិនបើមានកិច្ចការបន្ថែមណាមួយគួរត្រូវបានដាក់បញ្ចូល និងកំណត់ពីទម្ងន់នៃបទសម្ភាសន៍ទាំងនោះ ក្រែងមានកិច្ចណាមួយនាំជាបច្ច័យដល់វិមតិសង្ស័យទៅលើសេចក្តីថ្លែងការណ៍ ប្រសិនបើអង្គជំនុំជម្រះអនុញ្ញាត"* ។[១៩] ក្រុមការពារក្តីចាត់ទុកថាបញ្ហានេះមានភាពចាំបាច់ជាពិសេស ពីព្រោះការិយាល័យសហព្រះរាជអាជ្ញាបានធ្វើសំណើសុំដាក់បញ្ចូលសេចក្តីថ្លែងការណ៍រាប់ពាន់ច្បាប់របស់សាក្សីជាច្រើននៅចំពោះមុខអង្គជំនុំជម្រះ ដោយមិនបានកោះហៅសាក្សីទាំងនោះមកធ្វើសក្ខីកម្មឡើយ។

នៅក្នុងលិខិតស្នើរបស់ខ្លួន ក្រុមការពារក្តីរបស់លោក **អៀង សារី** បានកត់សម្គាល់ទៅលើការរកឃើញ១២ករណីបន្ថែម ដែលពាក់ព័ន្ធនឹងអ្នកស៊ើបអង្កេតមិនបានធ្វើកំណត់ហេតុក្នុងពេលធ្វើបទសម្ភាសន៍ជាមួយសាក្សី ហើយករណីបន្ថែមទាំងនោះ ត្រូវបានក្រុមការពារក្តីបានលើកឡើងទាំងនៅក្នុងសំណើមុនៗ និងនៅក្នុងបន្ទប់សវនាការ ។[២០] ដោយឈរលើមូលដ្ឋាននេះហើយ ដែលក្រុមការពារក្តីបានពោលអះអាងថា ការអនុវត្តនីតិវិធីធ្វើបទសម្ភាសន៍ដោយមិនមានកំណត់ហេតុ*"គឺត្រូវបានអនុវត្តយ៉ាងទូលំទូលាយ និងមានលក្ខណៈជាប្រព័ន្ធ ហើយដែលប្រការទាំងនេះអាចនឹងអភ័យទោសឲ្យបាន ប្រសិនបើវាមិនមែនជាការជម្រុញលើកទឹកចិត្តយ៉ាងសកម្មពីសហចៅក្រមស៊ើបអង្កេតដោយផ្ទាល់ទេ ពោលគឺថាវាជាការគួរឲ្យព្រួយបារម្ភបើ ៖ វាជាវិធានមួយដែលរៀបចំឲ្យអនុវត្តតាមពីថ្នាក់លើខ្ពស់បំផុតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត"* ។ ក្រុមការពារក្តីបានតវ៉ាថា ទង្វើនេះប៉ះពាល់ដល់សិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌របស់លោក **អៀង សារី** ហើយជាពិសេសធ្វើឲ្យកើនឡើងនូវបន្ទុកក្នុងកិច្ចការពារក្តីយ៉ាងក្រាស់ក្រែល ក៏ដូចជាបន្ទុកក្នុងការធ្វើកោសល្យវិច័យលើភស្តុតាងប្រឆាំងនឹងជនជាប់ចោទ ។[២១]

## ខ. ការតាំងសំណួរដេញដោលលើចម្លើយរបស់តតិយជន

កិច្ចពិភាក្សា បានបន្តដោយផ្តោតលើបញ្ហានៃការតាំងសំណួររបស់ភាគីក្នុងការប្រើប្រាស់កំណត់ហេតុរបស់អ្នកជំនាញ ឬចម្លើយរបស់តតិយជន (ជនទីបី) ដើម្បីយោងក្នុងពេលសួរសំណួរ ។ ព្រះរាជអាជ្ញាអន្តរជាតិ លោក **ឌេល លីសាក់** (Mr. Dale Lysak) បានលើកឡើងថា នេះជាការត្រឹមត្រូវដែលអនុញ្ញាតឲ្យភាគីតាំងសំណួរផ្អែកលើចម្លើយរបស់តតិយជនដែលមានវត្តមានក្នុងព្រឹត្តិការណ៍ជាប់វិមតិសង្ស័យនេះ ល្គឹកណាការតាំងសំណួរដេញដោលរបស់ក្រុមមេធាវី បានបង្កើតជាទំនាក់ទំនងដោយផ្ទាល់រវាងសាក្សីពាក់ព័ន្ធនឹងបុគ្គលដែលបានផ្តល់ចម្លើយ ឬខ្លឹមសារនៃចម្លើយរបស់បុគ្គលនោះ ។ ទោះជាយ៉ាងនេះក្តី ព្រះរាជអាជ្ញា **លីសាក់** បានជំទាស់នឹងការតាំងសំណួររបស់មេធាវី **ប៉ៅ** ដែលបានយោងលើបទសម្ភាសន៍របស់លោកសាស្ត្រាចារ្យ **បេន ខៀណាន់** (Pro. Ben Kiernan) ជាមួយលោក **ហេង សំរិន** ពីព្រោះព្រះរាជអាជ្ញាយល់ថាលោក **ប៉ៅ** មិនបានបង្ហាញពីទំនាក់ទំនងដែលពាក់ព័ន្ធនឹងសំណួរឡើយ ហើយគាត់បានបង្ហាញពីក្តីបារម្ភថា លោក **ប៉ៅ** បានសួរដឹកមុខសាក្សី ឬសួរដើម្បីឲ្យសាក្សីឆ្លើយតាមអ្វីដែលខ្លួនរំពឹងទុក ។ ជាមួយគ្នានេះផងដែរ លោក **លីសាក់** បានចោទលោក **ប៉ៅ** ថាមានបំណងធ្វើជាមិនដឹងមិនឮក្នុងការដែល

និយាយថា គាត់មិនយល់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទាក់ទងនឹងការយោង ឬដកស្រង់នូវសេចក្តីថ្លែងការណ៍របស់អ្នកជំនាញ និងចម្លើយរបស់បុគ្គលផ្សេងមកធ្វើជាសម្អាងក្នុងការសួរដេញដោល ។

រីឯលោក **ប៉ៅ** បានបន្តការតាំងសំណួរដេញដោលរបស់ខ្លួនដោយផ្អែកលើបទសម្ភាសន៍លោក **ខៀណាន់** ជាមួយលោក **ហេង សំរិន** និងបានដកស្រង់ខ្លឹមសារខ្លះៗពីសៀវភៅរបស់លោក **ម៉ៃខល វីគើរី** (MichaelVickery) ដែលមានចំណងជើងថា *"ប្រទេសកម្ពុជាពីឆ្នាំ១៩៧៥ ដល់១៩៨២"* ។ តែទោះជាយ៉ាងនេះក៏ដោយ ក៏លោក **ប៉ៅ** បានអះអាងតបថាគាត់នឹងគោរពតាមរាល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ល្គឹកណាដែលសេចក្តីសម្រេចទាំងនោះបានលាតត្រលាងយ៉ាងជាក់លាក់ពីបទដ្ឋានអ្វីដែលត្រូវបានយកមកសម្អាង ហើយសេចក្តីសម្រេចនោះទៀតសោតត្រូវឈរលើមូលដ្ឋានសមស្របផងដែរ ។ ចំពោះលោកមេធាវី **កាណាវ៉ាស** បានធ្វើការកត់សម្គាល់ថា ភាគីទាំងអស់ត្រូវបានអនុញ្ញាតឲ្យតាំងសំណួរដេញដោល ទៅលើកំណត់ហេតុផ្ទាល់ដៃរបស់អ្នកជំនាញកាលពីសវនាការមុនៗ។ លោកមេធាវីបានអះអាងបន្ថែមថា ទោះបីជាមានសេចក្តីសម្រេចបែបនោះក៏ដោយ ក៏ការរក្សាតុល្យភាពរវាងបទចោទប្រកាន់ និងការការពារក្តីជនជាប់ចោទ ត្រូវតែទទួលការធានា ។

អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចដូចពីមុនដែរ គឺមិនអនុញ្ញាតឲ្យលោក **ប៉ៅ** តាំងសំណួរដេញដោលដោយផ្អែកលើបទសម្ភាសន៍របស់លោក **ខៀណាន់** ជាមួយលោក **ហេង សំរិន** ឬផ្អែកលើមតិយោបល់របស់អ្នកជំនាញផ្នែកប្រវត្តិសាស្ត្រណាមួយ ដូចជាលោក **វីគើរី** (Mr. Vickery) ឬ លោក **ហ្វីលីព ស៊ត** (Mr. Philip Short) ជាដើម។ល។ គួរកត់សម្គាល់ថា អង្គជំនុំជម្រះបានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាប្រើប្រាស់ចម្លើយសាក្សីជាទាហានម្នាក់ទៀត ធ្វើជាសម្អាងក្នុងការសួរដេញដោលលោក **ស៊ុំ ជា** ។ សាក្សីនោះធ្លាប់នៅក្នុងកងវរសេនាតូចជាមួយសាក្សីបច្ចុប្បន្ន( **ស៊ុំ ជា**) ក្នុងភូមិភាគឧត្តរ អំឡុងពេលនៃការរំដោះទីក្រុងភ្នំពេញ ។

## គ. ការស្នើសុំឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានឱកាសឆ្លើយនូវអង្គហេតុទាំងមូលក្នុងសំណុំរឿង០០២

មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីលោក **ហុង គឹមសួន** បានស្នើសុំទៅអង្គជំនុំជម្រះអនុញ្ញាតឲ្យលោកស្រី **មុម សំអឿន** ផ្តល់សក្ខីកម្មទៅលើគ្រប់សាច់រឿងទាំងអស់ដែលស្ថិតក្នុងសំណុំរឿង ០០២ ពីព្រោះអាយុកាលវ័យចំណាស់របស់អ្នកស្រី អាចជាឧបសគ្គរាំងដល់ការផ្តល់សក្ខីកម្មលើផ្នែកបន្តបន្ទាប់នៃសវនាការវគ្គក្រោយៗទៀត ។ គួរបញ្ជាក់ថាបច្ចុប្បន្ននេះ អ្នកស្រី **មុម សំអឿន** មានអាយុប្រហែលចន្លោះពី៨៥ឆ្នាំ ទៅ៨៧ឆ្នាំ ។ អង្គជំនុំជម្រះមិនបានអនុញ្ញាតឲ្យអ្នកស្រី **មុម សំអឿន** មានឱកាសឆ្លើយតបនូវរាល់អង្គហេតុដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២ ទាំងមូលនោះទេ ក៏ប៉ុន្តែបានអនុញ្ញាតឲ្យអ្នកស្រីថ្លែងរៀបរាប់ពីទុក្ខសោកវេទនារបស់អ្នកស្រីនៅក្នុងសំណុំរឿង ០០២ ដោយមិនកំណត់ពេលវេលានៅចុងបញ្ចប់នៃសក្ខីកម្មរបស់អ្នកស្រី ។

## ឃ. ការជំទាស់នឹងសំណួរនាំមុខ

ភាគីទាំងអស់ បានបន្តការជជែកវែកញែកលើរបៀបសួរសំណួរឲ្យបានសមរម្យ ក៏ដូចជាការជំទាស់ទៅនឹងសំណួរដឹកមុខមួយចំនួនផងដែរ ។ នាសប្តាហ៍នេះ សហព្រះរាជអាជ្ញាបានជំទាស់នឹងការតាំងសំណួររបស់មេធាវី **ប៉ៅ** ជាច្រើនលើកច្រើនសា ជាពិសេសចំពោះសំណួរទាំងឡាយណាដែលបានដកស្រង់ចេញពីចម្លើយរបស់លោក **ហេង សំរិន** ក្នុងពេលគាត់ផ្តល់បទសម្ភាសន៍ឲ្យលោកសាស្ត្រាចារ្យ **បេន ខៀណាន់** ។ ការជំទាស់នេះ ត្រូវបានសម្អាងលើ

ភាពគ្មានទំនាក់ទំនងដោយផ្ទាល់រវាងសាក្សី និងលោក **ហេង សំរិន** ហើយថាការបង្ហាញសេចក្តីថ្លែងការណ៍របស់បុគ្គលផ្សេងដល់សាក្សីមុនពេលសួរគាត់ និងក៏មិនទាន់បានទទួលចម្លើយដែលឆ្លុះបង្ហាញពីភាពពាក់ព័ន្ធនៅឡើយ គឺជាការមិនសមស្រប ។ ព្រះរាជអាជ្ញាបន្តថា ទង្វើនេះមានន័យថា មេធាវីការពារក្តីបានសួរក្នុងបំណងបំផុសឲ្យសាក្សីឆ្លើយតាមការប្រាថ្នាចង់បានរបស់ខ្លួន ។ ព្រះរាជអាជ្ញាបានស្នើថា វាអាចនឹងសមរម្យក្នុងការសួរសំណួរជាទូទៅសិនបន្ទាប់មកទាញចូលទៅក្នុងផ្នែកជាក់លាក់នានា ផ្អែកលើសក្ខីកម្មរបស់បុគ្គលណាមួយ ប្រសិនបើក្រុមមេធាវីការពារក្តីចាប់ផ្តើមបង្កើតពីភាពពាក់ព័ន្ធតាមរយៈការសួររបស់ខ្លួន ដោយបង្ហាញពីបទពិសោធន៍ក្នុងសក្ខីកម្មរបស់បុគ្គលផ្សេងនោះ ថាមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងរឿងរ៉ាវរបស់សាក្សីបច្ចុប្បន្ន ។

សប្តាហ៍នេះ លោកមេធាវី **កាណាវ៉ាស** ក៏បានធ្វើការជំទាស់នឹងការតាំងសំណួរជាក់លាក់មួយចំនួនរបស់សហព្រះរាជអាជ្ញាអន្តរជាតិ លោក **វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល** (Mr. Vincent de Wilde d'Estmael) ដោយធ្វើការតវ៉ាថា សហព្រះរាជអាជ្ញាកំពុងបង្កើតសំណួរដឹកមុខ ។ ជាងនេះទៅទៀត មេធាវី **កាណាវ៉ាស** បាននិយាយថាព្រះរាជអាជ្ញារូបនេះ បានទទួចយ៉ាងប្រាកដតាមរយៈការតាំងសំណួររបស់គាត់ជាច្រើន ដែលក្រោយ និងមុនការសួរសហព្រះរាជអាជ្ញាបានធ្វើសេចក្តីថ្លែងការណ៍ដូចប្រាប់ពីចម្លើយឲ្យសាក្សីឆ្លើយតាម ដែលទាំងនេះជាការមិនសមស្របនោះទេក្រោមមូលដ្ឋានថា វាជាការស្តែងចេញយ៉ាងច្បាស់នូវការដឹកមុខសាក្សី ។ សហព្រះរាជអាជ្ញាបានតវ៉ាថា សំណួររបស់គាត់មិនមែនជាការដឹកមុខសាក្សីទេ តែវាជាវិធីសាស្ត្រធ្វើឲ្យសំណួរដែលគាត់សួរកាន់តែមានភាពច្បាស់លាស់ថែមទៀត ។ អង្គជំនុំជម្រះ មិនបានដោះស្រាយបញ្ហានេះភ្លាមៗឡើយក្នុងអំឡុងនៃកិច្ចដំណើរការនីតិវិធីនាសប្តាហ៍នេះ ។ ជាញឹកញាប់នៅពេលមានការជំទាស់ចេញពីភាគីណាមួយ ភាគីម្ខាងទៀតនឹងធ្វើការជំទាស់ ហើយនៅពេលចប់ការលើកឡើង អង្គជំនុំជម្រះមិនបានធ្វើការដោះស្រាយនូវការលើកឡើងរបស់ភាគីឡើយ និងគ្រាន់តែប្រាប់ថា "មេធាវីសូមបន្តនីតិវិធី" ។[២២]

## *ជំពូកទី៤ ៖* លក្ខខណ្ឌសុខភាព និងបញ្ហាកាយសម្បទាលក្នុងការចូលរួមសវនាការរបស់លោក អៀង សារី

នៅថ្ងៃព្រហស្បតិ៍នេះ អង្គជំនុំជម្រះសាលាដំបូង បានស្តាប់របាយការណ៍របស់សាក្សីជាអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ គឺលោកវេជ្ជបណ្ឌិត **ចន ខាំប៊ែល** (John Campbell) ជុំវិញបញ្ហាស្ថានភាពសុខភាពរបស់លោក **អៀង សារី** និងបញ្ហាកាយសម្បទាក្នុងការចូលរួមសវនាការ ។ តបតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង លោកសាស្ត្រាចារ្យ **ខាំប៊ែល** បានធ្វើការត្រួតពិនិត្យព្យាបាលសុខភាពរបស់ជនជាប់ចោទបីរូប មាន៖ លោក **អៀង សារី** អ្នកស្រី **អៀង ធីរិទ្ធ** និងលោក **នួន ជា** ហើយថ្មីៗនេះកាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១២ លោកសាស្ត្រាចារ្យ ត្រូវបានអង្គជំនុំជម្រះកោះហៅមកផ្តល់សក្ខីកម្មដើម្បីមានឱកាសរាយការណ៍ លទ្ធផលដែលបានពីការពិនិត្យ ។ ក្នុងកាលៈទេសៈនេះ លោកសាស្ត្រាចារ្យ **ខាំប៊ែល** បានរៀបរាប់ឡើងវិញនូវរបាយការណ៍ដែលបានធ្វើរួមគ្នាជាមួយវេជ្ជបណ្ឌិតផ្សេងទៀត សង្ខេបពីប្រតិចារឹកនៃសក្ខីកម្មរបស់ពួកគាត់នៅមុខអង្គជំនុំជម្រះកាលពីលើកមុន និងបង្ហាញផងដែរនូវឯកសារពាក់ព័ន្ធពីស្ថានភាពសុខភាពរបស់លោក **អៀង សារី** មុននឹងធ្វើការត្រួតពិនិត្យ ។ លោកសាស្ត្រាចារ្យ បានតាមដានពិនិត្យជម្ងឺរបស់ជនជាប់ចោទក្នុងអំឡុងពីរថ្ងៃជាង ហើយបានរកឃើញថាជនជាប់ចោទមានកាយសម្បទា និងសតិស្មារតីគ្រប់គ្រាន់ អាចចូលរួមតាមដានកិច្ចដំណើរការនីតិវិធីក្នុងសវនាការបាន ។

## ក. មតិយោបល់អ្នកជំនាញ

លោកសាស្ត្រាចារ្យ **ខាំប៊ែល** បានរកឃើញថា លោក **អៀង សារី** មានជម្ងឺឈឺក្បាល ឈឺឆ្អឹងខ្នង និងជម្ងឺបេះដូងធ្ងន់ធ្ងរ ។ លោកសាស្ត្រាចារ្យ បានបញ្ជាក់ពីស្ថានភាពសុខភាពរបស់លោក **អៀង សារី** ថាអាចធ្វើការសន្ទនាបាននៅពេលដែលគាត់ទម្រេតខ្លួន ក៏ប៉ុន្តែគាត់ងាយនឹងទទួលអាការៈឈឺក្បាល ប្រសិនបើគាត់អង្គុយយូរពេក ។ ក្នុងនោះផងដែរ លោកសាស្ត្រាចារ្យមិនបានរកឃើញថា មានអាការៈផ្លាស់ប្តូរណាមួយនៃលទ្ធភាពចងចាំរបស់លោក **អៀង សារី** ឡើយ ហើយលោកសាស្ត្រាចារ្យ បានជឿជាក់ថាលោក **អៀង សារី** មានកាយសម្បទាក្នុងការចូលរួមសវនាការបាន ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនៃសំណុំរឿងរបស់លោក **ស្ទ្រូហ្គា** ( Strugar)[២៣] ពោលគឺមានលទ្ធភាពទាំងស្មារតី និងកាយសម្បទាគ្រប់គ្រាន់ដើម្បីតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំឃាំងជាន់ក្រោមសាលសវនាការ ។ តែទោះជាយ៉ាងនេះក្តី លោកសាស្ត្រាចារ្យមិនបានបញ្ជាក់ឲ្យច្បាស់ថាតើនឹងមានអ្វីកើតឡើងចំពោះលោក **អៀង សារី** ប្រសិនបើមានសំណើសុំឲ្យគាត់ផ្តល់សក្ខីកម្ម។

ក្នុងការឆ្លើយតបទៅនឹងសំណួរដេញដោលពីសំណាក់ក្រុមប្រឹក្សាអង្គជំនុំជម្រះ ធ្វើឡើងតាមរយៈចៅក្រមអន្តរជាតិ **ស៊ីលវៀ ខាតរ៉ាយថ៍** (Silvia Cartwright) លោកសាស្ត្រាចារ្យ **ខាំប៊ែល** បានគូសបញ្ជាក់ថា មិនមានការចាំបាច់ឡើយក្នុងការតម្រូវឲ្យលោក **អៀង សារី** ស្នាក់នៅក្នុងមន្ទីរពេទ្យទេ ក៏ប៉ុន្តែត្រូវមានការថែទាំសុខភាពរបស់លោកឲ្យបានជិតដល់ក្នុងមណ្ឌលឃុំឃាំង ដោយសុំឲ្យមានជំនួយការថែទាំផ្ទាល់បន្ថែមទៀត ដើម្បីជួយសម្រួលដល់ការធ្វើចលនាចុះឡើងរបស់គាត់ ។ លោកមេធាវី **កាណាវ៉ាស** បានចាត់តាំងវេជ្ជបណ្ឌិតផ្សេងទៀតល្បងតេស្តសុខភាពកូនក្តីខ្លួន ដោយបានសម្ភាសន៍ជាមួយលោក **អៀង សារី** បានត្រឹមតែ១៥នាទី ប៉ុណ្ណោះ លោក **អៀង សារី** បានសុំសម្រាក ។ ក្នុងករណីនេះ លោកមេធាវីបានចោទសួរទៅកាន់លោកសាស្ត្រាចារ្យ **ខាំប៊ែល** ថាតើវាអាចទៅរួចទេដែលអ្នកជំងឺម្នាក់អាចឆ្លើយសំណួរបានតែ១៥នាទីគត់ មានសមត្ថភាពចូលរួមក្នុងការការពារក្តីរបស់ខ្លួនបាន។ លោក **ខាំប៊ែល** បានឆ្លើយតបថា អ្វីដែលលោកមេធាវី **កាណាវ៉ាស** បានលើកឡើងមិនមែនជាការសង្កេតរបស់គាត់ឡើយ (ជាការពិនិត្យរបស់វេជ្ជបណ្ឌិតផ្សេង) ។ ប្រការនេះ នាំឲ្យលោកមេធាវី **កាណាវ៉ាស** កាត់សម្តីលោក **ខាំប៊ែល** ភ្លាមៗ ដោយនិយាយថា *"ខ្ញុំមិនមែនចង់មានន័យអញ្ចឹងទេ តែខ្ញុំកំពុងសួរលោកពីសេណារីយ៉ូ (សភាពការៈ)ទេតើ"* ។ ទោះបីជាយ៉ាងនេះក្តី លោកសាស្ត្រាចារ្យ **ខាំប៊ែល** បានគេចវេសនូវសំណួរខាងលើនេះយ៉ាងមានប្រសិទ្ធភាព ។

## ខ. បទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធនឹងបញ្ហាកាយសម្បទាក្នុងការចូលរួមសវនាការ

លក្ខណៈវិនិច្ឆ័យលើកាយសម្បទាដែលធ្លាប់ប្រើជាទូទៅ ត្រូវបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងនៃ *តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី* (ICTY) ឬហៅថា **អាយស៊ីធីវ៉ាយ** ក្នុងសំណុំរឿងលោក **ផាវលី ស្ទ្រូហ្គា** (Pavle Strugar) ។ លក្ខណៈវិនិច្ឆ័យលើកាយសម្បទាក្នុងសំណុំរឿងលោក **ស្ទ្រូហ្គា** (Strugar) តម្រូវឲ្យបុគ្គលនោះបំពេញនូវលក្ខខណ្ឌដូចខាងក្រោមៈ

- អាចធ្វើការអះអាងការពារខ្លួន
- យល់ដឹងពីបទចោទប្រកាន់
- យល់ដឹងពីកិច្ចដំណើរការនីតិវិធី
- យល់ដឹងពីព័ត៌មានលម្អិតនៃភស្តុតាង

- អាចប្រឹក្សាយោបល់ជាមួយមេធាវី
- យល់ដឹងពីផលវិបាកដែលកើតចេញពីកិច្ចដំណើរការនីតិវិធី និងអាចផ្តល់សក្ខីកម្ម។[២៤]

អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ **អាយស៊ីធីវ៉ាយ** បានបញ្ជាក់បន្ថែមថា បញ្ជីលក្ខណៈវិនិច្ឆ័យខាងលើនេះ មិនផុតរលត់ឡើយ និងថាៈ

> *វាអាចនឹងមិនសមរម្យ និងមិនត្រូវតាមបទដ្ឋានដែលធ្លាប់អនុវត្តកន្លងមកទេ ហើយវាប្រឆាំងទាំងស្រុងទៅលើការអនុវត្តន៍ច្បាប់អន្តរជាតិ ដែលតម្រូវឲ្យសមត្ថភាពនីមួយៗដែលបានថែងដូចខាងលើត្រូវតែធ្វើការបង្ហាញក្នុងឋានានុក្រមខ្ពស់បំផុត ឬក្នុងកម្រិតថ្នាក់លើបំផុតដែលជនជាប់ចោទជាក់លាក់ណាមួយធ្លាប់បានទទួលយកពីមុន...ជាការគួរអ្វីដែលតម្រូវឲ្យមាននោះ គឺជាការកម្រិតឲ្យនៅទាបបំផុតសម្រាប់លក្ខខណ្ឌសមត្ថភាពកម្រិតទាបទាំងអស់ ដែលជនជាប់ចោទម្នាក់មិនអាចត្រូវទទួលបាននូវការជំនុំជម្រះដោយមិនភាពយុត្តិធម៌ឡើយ ។*[២៥]

តាមវិធីនេះ នាំឲ្យអង្គជំនុំជម្រះទុកចន្លោះពេលជាច្រើន ដើម្បីធ្វើសេចក្តីសម្រេចទៅលើករណីម្តងមួយៗ ។[២៦] ជាងនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ **អាយស៊ីធីវ៉ាយ** បានរកឃើញថា ការផ្តល់ជំនួយតាមរយៈមេធាវីប្រឹក្សាក្តី ជាការទូទាត់គ្រប់គ្រាន់សម្រាប់ការបាត់បង់សមត្ថភាពរបស់ជនជាប់ចោទ និងធ្វើឲ្យកិច្ចដំណើរការនីតិវិធីជំនុំជម្រះលើជនជាប់ចោទមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ ។[២៧] ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះបានទទួលស្គាល់ថា ជនជាប់ចោទត្រូវមានកម្រិតយល់ដឹងពិតប្រាកដមួយ ដើម្បីមានឱកាសគ្រប់គ្រាន់ក្នុងការប្រើប្រាស់មេធាវីប្រឹក្សាក្តីរបស់ខ្លួនបានពេញលេញ ជាប្រយោជន៍ដល់ការចូលរួមសវនាការប្រកបដោយប្រសិទ្ធភាព និងយុត្តិធម៌។[២៨]

លោក **ខាំប៊ែល** បានថ្លែងរៀបរាប់ពីចំណុចនីមួយៗនៃលក្ខណៈវិនិច្ឆ័យលើកាយសម្បទាចេញពីសក្ខីកម្មផ្ទាល់មាត់ និងពីសំណុំរឿងលោក **ស្ទ្រូហ្គា** ក្នុងរបាយការណ៍របស់គាត់ផងដែរ ដោយបានគូសបញ្ជាក់ថា គាត់បានរកឃើញនូវសមត្ថភាពសម្បទារបស់លោក **អៀង សារី** បានឆ្លើយតបទៅនឹងចំណុចនីមួយៗនៃបទដ្ឋានខាងលើនេះ ។ ចំណែកឯសមត្ថភាពសម្បទាក្នុងការផ្តល់សក្ខីកម្មវិញ លោកសាស្ត្រាចារ្យ បាននិយាយដោយសាមញ្ញថា *"លោក **អៀង សារី** មានសម្បទាល្អក្នុងការយល់ដឹងពីនីតិវិធីរបស់សវនាការ ដោយគាត់បានដឹងថា ដំបូងគាត់នឹងត្រូវបានសួរដោយចៅក្រម បន្ទាប់មកដោយសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ហើយចុងក្រោយគាត់ត្រូវសួរដោយក្រុមមេធាវីប្រឹក្សាក្តីរបស់សហជនជាប់ចោទ និងបញ្ចប់ដោយមេធាវីប្រឹក្សាក្តីផ្ទាល់របស់គាត់"* ។ គួរកត់សម្គាល់ថា លោកសាស្ត្រាចារ្យ មិនបានថ្លែងពីសមត្ថភាពសម្បទារបស់លោក **អៀង សារី** ក្នុងផ្តល់សក្ខីកម្មនោះទេ ។ ចំណែកឯសមត្ថភាពនៅក្នុងការណែនាំមេធាវីប្រឹក្សាវិញលោកសាស្ត្រាចារ្យ **ខាំប៊ែល** បានរកឃើញថាលោក **អៀង សារី** បានបង្ហាញពីយុទ្ធសាស្ត្រស្របគ្នាក្នុងផ្នែកការពារក្តី និងមានការចងចាំពីរឿងរ៉ាវនៃរបបខ្មែរក្រហមបានល្អ ។ ដូច្នេះហើយទើបលោកសាស្ត្រាចារ្យបានសន្និដ្ឋានបញ្ចប់ថា លោក **អៀង សារី** មានសមត្ថភាពសម្បទាពេញលេញក្នុងការផ្តល់ព័ត៌មានឲ្យមេធាវីប្រឹក្សាក្តីស្តីពីទស្សនៈវិស័យរបស់គាត់ទៅលើព្រឹត្តិការណ៍ និងប្រធានបទផ្សេងៗទៀត ដែលមេធាវីប្រឹក្សាក្តីរបស់គាត់អាចយកទៅប្រើប្រាស់ក្នុងកិច្ចការពារក្តីបាន ។

### គ. ការអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តីដទៃទៀតធ្វើសេចក្តីថ្លែងការណ៍

មេធាវីប្រឹក្សាក្តីអន្តរជាតិរបស់លោក **នួន ជា** គឺលោក **អេនឌ្រូ អ៊ីនូហ្ស៊ី** (Andrew Ianuzzi) បានជំទាស់នឹងការស្នើសុំពេលវេលាបន្ថែមរបស់ការិយាល័យសហព្រះរាជអាជ្ញាក្រោមហេតុផលថា វានឹងអាចកាត់បន្ថយពេលវេលាពីភាគីផ្សេងទៀតក្នុងការសម្តែងមតិយោបល់លើសក្ខីកម្មរបស់លោកសាស្ត្រាចារ្យ **ខាំប៊ែល** ។ ប្រធានតុលាការ ចៅក្រម **និល ណុន** បានឆ្លើយតបថា លោកមេធាវី **អ៊ីនូហ្ស៊ី** នឹងមិនមានឱកាសក្នុងការសម្តែងមតិយោបល់ទេ និងថាអង្គជំនុំជម្រះបានបញ្ជាក់រួចរាល់ហើយ គឺមានតែភាគីដែលពាក់ព័ន្ធ ពោលគឺមានមេធាវីការពារក្តីរបស់លោក **អៀង សារី** ភាគីសហព្រះរាជអាជ្ញា និងភាគីដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ដែលត្រូវបានផ្តល់ឱកាសក្នុងការធ្វើសេចក្តីថ្លែងការណ៍នៅក្នុងសវនាការថ្ងៃនេះ ។ លោកប្រធានក៏បានគូសបញ្ជាក់ប្រាប់ថា ទាំងមេធាវី **អ៊ីនូហ្ស៊ី** និងមេធាវីអន្តរជាតិរបស់លោក **ខៀវ សំផន** គឺលោក **អាកធួរ វែកគែន** (Arthur Vercken) អាចមានវត្តមានក្នុងនាមជាអ្នកសង្កេតការណ៍តែប៉ុណ្ណោះ ។ បន្ទាប់មក លោកមេធាវី **អ៊ីនូហ្ស៊ី** បានព្យាយាមធ្វើការថ្លែងតប ប៉ុន្តែត្រូវប្រធានតុលាការកាត់ផ្តាច់ចំនួនបីលើក ដោយនិយាយដដែលៗថា *“លោកមេធាវី មានវត្តមាននៅទីនេះសម្រាប់តែធ្វើការសង្កេតការណ៍តែប៉ុណ្ណោះ។ សូមទៅពិនិត្យរកមើលអត្ថន័យនៃពាក្យអ្នកសង្កេតការណ៍ឡើងវិញ បើលោកមិនទាន់យល់ច្បាស់ទេ”* ។

នៅចុងបញ្ចប់នៃសវនាការថ្ងៃអង្គារនេះ អង្គជំនុំជម្រះបានបញ្ជាក់ថា មានតែភាគីដែលពាក់ព័ន្ធតែប៉ុណ្ណោះនឹងត្រូវបានអនុញ្ញាតឲ្យចូលរួមសវនាការនៅថ្ងៃព្រហស្បតិ៍នេះ ។ ការលើកឡើងបែបនេះ មិនមានភាពច្បាស់លាស់ថាតើសវនាការនឹងត្រូវបិទ ឬបើកជាសាធារណៈ ហើយថាតើភាគីជាក់លាក់ណាខ្លះអាចចូលរួមសវនាការនេះបាន ។ នៅព្រឹកថ្ងៃព្រហស្បតិ៍នេះ ប្រធានតុលាការបានបញ្ជាក់ប្រាប់ថា ចិរវេលានៃសវនាការនេះ គឺសម្រាប់លៃទុកឲ្យភាគីនីមួយៗដែលពាក់ព័ន្ធ មានដូចជា៖ ក្រុមការពារក្តីលោក **អៀង សារី** តំណាងសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ហើយ*“ភាគីទាំងអស់ នឹងមានឱកាសសម្តែងមតិយោបល់ក្នុងវគ្គបញ្ចប់នៃសវនាការ”* ។ ផ្អែកលើចំណុចត្រង់នេះហើយដែលធ្វើឲ្យមានការភាន់ច្រឡំ ដូចដែលលោកមេធាវី **អ៊ីនូហ្ស៊ី** បានយល់ថាការថ្លែងបែបនេះ គឺរួមបញ្ចូលទាំងខ្លួនគាត់ និងក្រុមការពារក្តីលោក **ខៀវ សំផន** ផងដែរ ។

## *ជំពូកទី៥ ៖* ការគ្រប់គ្រងសវនាការ

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូងបានជួបប្រទះនឹងវិវាទកម្មមួយចំនួនទាក់ទងនឹងបញ្ហាផ្នែកច្បាប់ និងនីតិវិធីក្នុងអំឡុងពេលនៃការធ្វើសក្ខីកម្មរបស់សាក្សី **ស៊ុំ ជា** និងអ្នកជំនាញ **ចន ខាំប៊ែល** ។ នៅថ្ងៃច័ន្ទ ការជំទាស់ពីសំណាក់ក្រុមមេធាវីការពារក្តី បានធ្វើឡើងទៅលើបញ្ហាដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ភស្តុតាង រីឯនៅថ្ងៃព្រហស្បតិ៍វិញ ទាក់ទងនឹងគុណភាពនៃការធ្វើកោសល្យវិច័យរបស់អ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ។ ទោះបីជាបញ្ហាខាងលើនេះ បានពន្យឺតដល់កិច្ចដំណើរការនីតិវិធីយ៉ាងណាក៏ដោយ ក៏វាមិនបានប៉ះពាល់ដល់កិច្ចបិទបញ្ចប់អង្គសវនាការតាមផែនការដែលបានគ្រោងទុកដែរ ។ មានតែករណីនៃការជំទាស់ពីរ ឬបីតែប៉ុណ្ណោះ ដែលត្រូវបានលើកឡើងក្នុងអំឡុងពេលនៃការសួរដេញដោលទៅលើដើមបណ្តឹងរដ្ឋប្បវេណី អ្នកស្រី **មុម សំអឿន** ប៉ុន្តែត្រូវបានអង្គជំនុំជម្រះដោះស្រាយទាន់សភាពការណ៍ ។

## ក.	វត្តមាន

លោក **អៀង សារី** បានបន្តអវត្តមានពីបន្ទប់សវនាការពេញមួយសប្តាហ៍នេះ ។ ទោះបីជាយ៉ាងនេះក្តី គាត់ត្រូវបានអនុញ្ញាតឲ្យចេញពី*មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត* (Khmer-Soviet Friendship Hospital) ដើម្បីអាចចូលរួមស្តាប់សវនាការស្តីពីបញ្ហាកាយសម្បទារបស់គាត់ក្នុងការចូលរួមសវនាការ ប៉ុន្តែបានតាមដានពីបន្ទប់ឃុំឃាំងជាន់ក្រោមសាលសវនាការភ្ជាប់ដោយប្រព័ន្ធសោតទស្សន៍ កាលពីថ្ងៃព្រហស្បតិ៍នេះ ។ លោក **នួន ជា** បានចូលរួមក្នុងបន្ទប់សវនាការពេលព្រឹក និងបានវិលត្រឡប់ទៅសម្រាកតាមដានសវនាការ ពីបន្ទប់ឃុំឃាំងជាន់ក្រោមសាលសវនាការនាវគ្គថ្ងៃរសៀលកាលពីថ្ងៃច័ន្ទ និងអង្គារនេះ ។ ដោយឡែកនៅថ្ងៃព្រហស្បតិ៍ គាត់មិនមានវត្តមាននោះទេ ដោយសារតែជាសវនាការលើបញ្ហាកាយសម្បទាក្នុងការចូលរួមសវនាការរបស់លោក **អៀង សារី** ។ រីឯលោក **ខៀវ សំផន** វិញ បានមានវត្តមានក្នុងបន្ទប់សវនាការគ្រប់វគ្គពិភាក្សាទាំងអស់លើកលែងតែថ្ងៃព្រហស្បតិ៍ ។

***វត្តមានភាគីដើមបណ្តឹងរដ្ឋប្បវេណី៖*** មានដើមបណ្តឹងរដ្ឋប្បវេណីប្រហែលពី១៥ ទៅ៣០នាក់ បានចូលរួមស្តាប់កិច្ចដំណើរការនីតិវិធីពីបន្ទប់សវនាការ និងខ្លះទៀតនៅសាលសាធារណជន ។

***វត្តមានភាគី៖*** ភាគីទាំងអស់មានវត្តមានត្រឹមត្រូវពេញមួយសប្តាហ៍នេះ លើកលែងតែនៅថ្ងៃច័ន្ទ ។ ក្រឡាបញ្ជីបានប្រកាសថា មេធាវីអន្តរជាតិការពារក្តីឲ្យលោក **ខៀវ សំផន** គឺលោក **អាកទួរ វែកគែន** នឹងមកយឺតប្រហែលជាមួយម៉ោង ។ ក្នុងអំឡុងពេលនៃសវនាការលើបញ្ហាកាយសម្បទារបស់លោក **អៀង សារី** ក្នុងការចូលរួមសវនាការកាលពីថ្ងៃព្រហស្បតិ៍នេះ ក្រុមមេធាវីជាតិ និងអន្តរជាតិការពារក្តីទាំងអស់របស់លោក **អៀង សារី** បានមានវត្តមានក្នុងបន្ទប់សវនាការ ។ លោកមេធាវី **អ៊ីនូហ្សី** និងលោកមេធាវី **វែកគែន** ក៏បានចូលរួមផងដែរ ក៏ប៉ុន្តែវត្តមានរបស់ពួកគាត់ គឺត្រឹមតែជាអ្នកសង្កេតការណ៍ទៅលើកិច្ចដំណើរការនីតិវិធីប៉ុណ្ណោះ ។

**វត្តមានសាធារណជនៈ**

| កាលបរិច្ឆេទ | សវនាការពេលព្រឹក | សវនាការពេលរសៀល |
|---|---|---|
| ថ្ងៃច័ន្ទ ០៥/១១/២០១២ | ▪ អ្នកភូមិ ២០០នាក់ មកពីខេត្តព្រៃវែង | ▪ អ្នកភូមិ ១០០នាក់ មកពីខេត្តតាកែវ<br>▪ អ្នកសង្កេតការណ៍បរទេស ២០នាក់ |
| ថ្ងៃអង្គារ ០៦/១១/២០១២ | ▪ សិស្សានុសិស្ស ៣០០នាក់ មកពីសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច<br>▪ ព្រះសង្ឃ ៨អង្គ<br>▪ អ្នកសង្កេតការណ៍បរទេស ៥នាក់ | ▪ អ្នកសង្កេតការណ៍បរទេស ២៧នាក់ មកពីអង្គការចិត្តសង្គមអន្តរវប្បធម៌ ហៅកាត់ថាTPO<br>▪ អ្នកភូមិ ១៥០នាក់ មកពីខេត្តកណ្តាល |
| ថ្ងៃព្រហស្បតិ៍ ០៨/១១/២០១២ | ▪ ព្រះសង្ឃ ១០០អង្គ<br>▪ អ្នកភូមិ ២៥០នាក់ មកពីខេត្តសៀមរាប<br>▪ អ្នកសង្កេតការណ៍បរទេស ២០នាក់ | ▪ អ្នកភូមិ ៥០នាក់ មកពីខេត្តកំពង់ចាម<br>▪ អ្នកសង្កេតការណ៍បរទេស ១០នាក់ |

## ខ. ការគ្រប់គ្រងពេលវេលា

បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានផ្អាកកិច្ចដំណើរការនីតិវិធីកាលពីថ្ងៃទី ២៩ ខែតុលារហូតដល់ថ្ងៃទី ២ ខែវិច្ឆិកា ដែលជាថ្ងៃឈប់សម្រាកថ្នាក់ជាតិចំនួនពីរថ្ងៃដាច់ដោយឡែកពីគ្នា សវនាការទើបតែបានចាប់ផ្តើមជាថ្មីនៅថ្ងៃច័ន្ទ អង្គារ និងព្រហស្បតិ៍ នាសប្តាហ៍នេះ ។ នៅថ្ងៃច័ន្ទ សវនាការលើសក្ខីកម្មរបស់លោក **ស៊ុំ ជា** បានប្រើអស់ពេលវេលាដែលបានផ្តល់ជូន ពោលគឺពេញមួយថ្ងៃ រីឯនៅថ្ងៃអង្គារវិញ សវនាការលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ្នកស្រី **មុម សំអឿន** បានបញ្ចប់មុនពេលវេលាដែលបានកំណត់ ដោយសារតែមេធាវីជាតិការពារក្តីលោក **នួន ជា** គ្រាន់តែសួរដេញដោលដោយសង្ខេបៗតែប៉ុណ្ណោះ ខណៈដែលមេធាវីមកពីពីរក្រុមផ្សេងទៀត មិនបានធ្វើការសួរដេញដោលអ្វីឡើយលើដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។

សវនាការនាសប្តាហ៍នេះ បានបញ្ចប់នៅថ្ងៃព្រហស្បតិ៍ បន្ទាប់ពីការស្តាប់សក្ខីកម្មរបស់អ្នកជំនាញវេជ្ជសាស្ត្រ លោក **ចន ខាំប៊ែល** ជុំវិញការវាយតម្លៃរបស់គាត់លើបញ្ហាកាយសម្បទារបស់លោក **អៀង សារី** ក្នុងការចូលរួមសវនាការ។ អង្គជំនុំជម្រះសាលាដំបូង និងភាគីនៃរឿងក្តីទាំងអស់ បានបញ្ចប់ការតាំងសំណួរដេញដោលទៅលើលោកសាស្ត្រាចារ្យ **ខាំប៊ែល** នៅចុងបញ្ចប់នៃសវនាការថ្ងៃព្រហស្បតិ៍នេះ ។

## គ. បរិយាកាសក្នុងបន្ទប់សវនាការ

លោកមេធាវី **កាណាវ៉ាស** បានសម្តែងអាកប្បកិរិយាខឹងសម្បាយ៉ាងខ្លាំងនាសប្តាហ៍នេះ ។ កាលពីថ្ងៃច័ន្ទគាត់បានបង្ហាញពីចេតនាមិនជឿជាក់លើសាក្សីលោក **ស៊ុំ ជា** និងបានចាត់ទុកបទសម្ភាសន៍ដែលសាក្សីរូបនេះបាន

ធ្វើជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេតថាមានវិមតិសង្ស័យ ។ កាលពីថ្ងៃអង្គារ គាត់បានជំទាស់នឹងរបៀបនៃការតាំងសំណួររបស់លោកព្រះរាជអាជ្ញា **វ៉ាយជ័ ដេស្មាឯល** ។ លោកមេធាវីបានលើកការជំទាស់របស់ខ្លួនជាមួយនឹងពាក្យសម្ដីពេញដោយកំហឹងដោយបាននិយាយយ៉ាងញាប់ដែលស្ដាប់មើលទៅសឹងតែមិនដូចជាការនិយាយ ប៉ុន្តែជាការស្រែកទៅវិញ ។ នៅថ្ងៃដដែលនេះគាត់បានសុំអភ័យទោសដោយនិយាយដោះសារថា“*សូមអធ្យាស្រ័យបាទ! ផឹកកាហ្វេច្រើនពេក*” ។ បន្ទាប់ពីការថ្លែងយ៉ាងដូចនេះមក លោកមេធាវីបានចាប់ផ្ដើមនិយាយយឺតៗ និងការពារអំណះអំណាងរបស់គាត់ដោយភាពរម្យទមវិញ ។ ក៏ប៉ុន្តែនៅថ្ងៃព្រហស្បតិ៍ មេធាវី **កាណាវ៉ាស** បានតម្លើងសម្លេងជាថ្មីនៅពេលគាត់តាំងសំណួរសួរដេញដោលសាក្សីជំនាញ **ចន ខាំប៉ែល** ។ ប្រការនេះ ជាហេតុនាំឲ្យមានការជំទាស់ជាបន្តបន្ទាប់ពីសំណាក់សហព្រះរាជអាជ្ញា និងមានការគាំទ្រពីអង្គជំនុំជម្រះតាមរយៈការព្រមានជាញយដង រីឯសាក្សីវិញទៀតសោត ក៏បានឆ្លើយតបខ្លីៗ និងតបតែនឹងសំណួរជាក់លាក់មួយចំនួនប៉ុណ្ណោះ ។ មានករណីមួយនោះ មេធាវី **កាណាវ៉ាស** បាននិយាយសង្កត់ទៅលើសាក្សី **ខាំប៉ែល** ថាសាក្សីរូបនេះបានឃើញរបាយការណ៍ដែលមានស្រាប់ពីមុនៗមក រៀបរាប់ពីស្ថានភាពរបស់លោក **អៀង សារី** ដែលនេះអាចជាមូលហេតុនាំឲ្យសាក្សី “ព្រហើន” ច្រានចោលនូវសំណួរមួយចំនួនរបស់គាត់ និងអាចនិយាយវាយតម្លៃបានថាតើវាមិនសូវមានតម្លៃ ឬមានផ្អែកទៅលើតែអ្វីដែលគាត់បានមើលពីក្នុងឯកសារពាក់ព័ន្ធនឹងប្រវត្តិសុខភាពរបស់លោក **អៀង សារី** ។ ភ្លាមៗបន្ទាប់ពីការជំទាស់របស់ភាគីព្រះរាជអាជ្ញា មេធាវី **កាណាវ៉ាស** បានដកពាក្យ “ព្រហើន” ដែលគាត់ទើបតែបានប្រើនេះ និងទទួលស្គាល់ថាពាក្យនេះវាធ្ងន់ធ្ងរពេកសម្រាប់សាក្សី ។

នាសប្ដាហ៍នេះផងដែរ ភាពនឹងធឹងរបស់ប្រធានតុលាការក៏ត្រូវបានពិសោធន៍មើល ។ លោកមេធាវី **អ៊ីនូហ្ស៊ី** បានព្យាយាមសួរទៅកាន់អង្គជំនុំជម្រះថាតើពេលណាដែលក្រុមរបស់លោកអាចមានពេលវេលាសម្ដែងនូវមតិយោល់ ឬធ្វើសេចក្ដីសន្និដ្ឋាន ជុំវិញការផ្ដល់សក្ខីកម្មរបស់អ្នកជំនាញ ។ នៅពេលនោះ ប្រធានតុលាការបានកាត់ផ្ដាច់ការលើកឡើងរបស់មេធាវី និងបានថ្លែងថា “លោកច្រឡំខ្លួនឯងទេ” គឺភាគីការពារក្ដីទាំងអស់ដោយមិនរាប់បញ្ចូលនូវក្រុមមេធាវីការពារក្ដីរបស់លោក **អៀង សារី** អាចមានវត្តមានក្នុងកិច្ចដំណើរការនីតិវិធីបាននៅពេលនេះ គ្រាន់តែជាអ្នកសង្កេតការណ៍ប៉ុណ្ណោះ និងមិនត្រូវបានអនុញ្ញាតឲ្យថ្លែងមតិយោបល់អ្វីឡើយ ។ បន្ទាប់មក ប្រធានតុលាការបានបង្គាប់ឲ្យមេធាវីរូបនេះអង្គុយចុះ ។ នៅពេលមេធាវី **អ៊ីនូហ្ស៊ី** បានក្រោកឈរឡើងចំនួនបីដងក្នុងបំណងស្នើសុំការបញ្ជាក់ទាក់ទងនឹងការផ្ដល់ព័ត៌មានដូចអង្គជំនុំជម្រះទើបតែបានថ្លែងនេះ ប្រធានតុលាការបានរារាំង និងច្រានចោលនូវការស្នើទាំងនោះជាមួយនឹងការនិយាយសម្លេងខ្លាំងៗ ។ នៅក្នុងការបកប្រែជាភាសាអង់គ្លេសក្នុងពេលឆ្លើយឆ្លងគ្នានេះត្រូវបានបកប្រែនៅក្នុងចំណុចដែលលោកប្រធាន **និល ណុន** ប្រាប់ទៅមេធាវី **អ៊ីនូហ្ស៊ី** មានខ្លឹមសារដូច្នេះថា៖ “លោកគ្រាន់តែជាអ្នកសង្កេតការណ៍តែប៉ុណ្ណោះ ដូច្នេះមិនអាចនិយាយអ្វីបានទេ” ។ តាមការនិយាយរបស់លោកប្រធានជាភាសាខ្មែរ ជាក់ស្ដែងគឺស្រួចស្រាវជាងនេះ មិនមែនត្រឹមតែប៉ុណ្ណឹងទេ ។ ប្រធានតុលាការ បាននិយាយថា “...យើងមិនដឹងថាតើលោកមានសិទ្ធិអ្វីនឹងធ្វើការលើកឡើងក្នុងសវនាការនេះទេ ។ យើងមិនឲ្យអ្នកឯងនិយាយទេ ពីព្រោះលោកចូលរួមក្នុងនាមអ្នកសង្កេតការណ៍ដោយមិនមានការអញ្ជើញរបស់យើង របស់អង្គជំនុំជម្រះទេនៅលើកនេះ ។ លោកពិនិត្យនូវស្ថានភាពក្នុងនាមជាអ្នកសង្កេតការណ៍តើមានលទ្ធភាពធ្វើអ្វីខ្លះ ។ យើងមិនអនុញ្ញាតឲ្យលោកនិយាយទេ ឲ្យលោកអង្គុយចុះ ហើយលោករៀនឡើងវិញអំពីបញ្ហានៃអ្នកសង្កេតការណ៍ធ្វើយ៉ាងដូចម្ដេច” ។

## ឃ. បញ្ហានៃការបកប្រែ និងបច្ចេកទេស

បន្ថែមលើបញ្ហាមួយចំនួនទាក់ទងនឹងការនិយាយឮចូលក្នុងម៉ៃក្រូហ្វូនជាប្រក្រតី សវនាការក៏ពើបប្រទះនូវបញ្ហានៃការបកប្រែភាសាផងដែរ។ កាលពីថ្ងៃអង្គារនេះ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកស្រី **មុម សំអឿន** អាចនិយាយ និងស្តាប់យល់ភាសាបារាំងបានយ៉ាងស្ទាត់ជំនាញ ដូច្នេះយើងបានសង្កេតឃើញថា គ្រាន់តែស្តាប់សំណួរដេញដោលពីលោកព្រះរាជអាជ្ញា **វ៉ាយជ៍ ដេស្មាឯល** ជាភាសាបារាំងរួចហើយ អ្នកស្រីក៏បានឆ្លើយតបភ្លាមៗ ដោយមិនចាំឲ្យមានការបកប្រែជាភាសាខ្មែរសិនឡើយ ដែលប្រការនេះ ជាហេតុនាំឲ្យមានចន្លោះពេលតិចតួចក្នុងការបកប្រែភាសា ។ នៅថ្ងៃព្រហស្បតិ៍វិញ មានការលំបាកកើតឡើងក្នុងការបកប្រែពីភាសាអង់គ្លេសទៅភាសាខ្មែរ ដោយសារតែលោកមេធាវី **កាណាវាស** បន្តសួរសំណួរពីមួយទៅមួយយ៉ាងលឿនទៅកាន់សាក្សីជំនាញលោកសាស្ត្រាចារ្យ **ចនខាំប៊ែល**។ ដោយមានការក្រើនរម្លឹកជាច្រើនដងពីសំណាក់ប្រធាន **និល ណុន** បញ្ហាដែលបានកើតឡើងខាងលើ ត្រូវបានដោះស្រាយដោយមិនមានការពន្យារពេលយូរឡើយ៕

## ង. តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្តើម | សម្រាកពេលព្រឹក | អាហារថ្ងៃត្រង់ | សម្រាកពេលរសៀល | ផ្អាកសវនាការ | រយៈពេលសវនាការសរុប |
|---|---|---|---|---|---|---|
| ថ្ងៃច័ន្ទ ០៥/១១/១២ | ៩:០០ | ១០:៥៨-១១:២៥ | ១២:១៥-១៣:៣៥ | ១៤:៥០-១៥:១០ | ១៦:១០ | ៥ម៉និង៣នាទី |
| ថ្ងៃអង្គារ ០៦/១១/១២ | ៩:០៣ | ១០:៣២-១០:៥៥ | ១២:១០-១៣:៣២ | ១៤:០៥ | - | ៣ម៉និង១៧នាទី |
| ថ្ងៃពុធ ០៧/១១/១២ | - | - | - | - | - | - |
| ថ្ងៃព្រហស្បតិ៍ ០៨/១១/១២ | ៩:១០ | ១០:៣២-១០:៥០ | ១២:០៧-១៣:៣២ | ១៤:២០-១៤:៤០ | ១៦:០៥ | ៤ម៉និង៥២នាទី |
| *រយៈពេលសវនាការជាមធ្យម* | | | | *៤ម៉ោង និង២៤នាទី* | | |
| *រយៈពេលសវនាការសរុបក្នុងសប្តាហ៍នេះ* | | | | *១៣ម៉ោង និង១២នាទី* | | |
| *ចំនួនម៉ោង ថ្ងៃ និងសប្តាហ៍នៃសវនាការ* | | | | *៥៥៥ម៉ោង និង១៥នាទី* | | |
| ***រយៈពេលសវនាការចំនួន ១២៦ ថ្ងៃ អំឡុងពេល ៣៨សប្តាហ៍*** | | | | | | |

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings;
- the figures in the *Public Attendance* section of the report are only approximations; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

*

*AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of **KRT TRIAL MONITOR** was authored by Samantha Lee, Danel Mattes, Aviva Nababan,SovannaSek, Kimsan Soy,and Penelope Van Tuyl, as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT

TRIAL MONITOR reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

[១] Sum Chea was examined in the following order: nationalProsecutor Chorvoin Song; international Prosecutor Dale Lysak; national Civil Party Lawyer Ty Srinna; international Civil Party Lawyer Nushin Sarkarati; Judge Jean-Marc Lavergne; national counsel for Nuon Chea, Mr. Son Arun; international counsel for Nuon Chea, Mr. Jasper Pauw; international counsel for Ieng Sary, Mr. Michael Karnavas.

[២] At the time of his testimony, Witness Sum Chea stated he was 59 years old.

[៣] Witness was unable to provide an exact date or month for the attack, other than 1975.

[៤] Sum Chea clarified that Hak was under the command of Mr. Voeung, the Division Commander, but he was unable to explain who above them originally ordered the citywide evacuation.

[៥] The record of Sum Chea's interview with OCIJ investigators has thedocument number D94/9.

[៦] The Witness did not know the names of other senior leaders, and he only made mention of Prince Sihanouk and Pol Pot, following this conference.

[៧] While evidence to the contrary has not been presented before the Court during the trial of Case 002, in Case 001 the author of the Gate, Francois Bizot, was summoned as a witness and his book was made as a reference for his examination. In the book, Bizot described that foreigners took refuge in the French Embassy after 17 Aprill 1975 for weeks before the Khmer Rouge arranged for them to be transported to the Thai Border.

[៨] In one example, the Witness stated that only North Zone forces were stationed around Wat Phnom, but Heng Samrin claimed that the East Zone occupied areas up to Wat Phnom as well.

[៩] Mom Sam Oeurn was examined in the following order: national Civil Party Lawyer Hong Kim Suon; international Civil Party Lawyer Beini Ye; national Prosecutor Chorvoin Song; international Prosecutor Vincent de Wilde d'Estmael; national Counsel for Nuon Chea, Mr. Son Arun. Civil Party was then offered the opportunity to make her Statement of Suffering.

[១០] At the time of her testimony, Mom Sam Oeurn stated she was 84 years old, making her one of the oldest people to testify so far in the trial. Her recollection of events in the DK, however, remained quite strong.

[១១] National Counsel for Nuon Chea, Mr. Son Arun, questioned the Civil Party regarding the period between 1970 and 17April1975, and her observations of events unfolding under the Lon Nol regime. Mom Sam Oeurn stated that she was not aware of any specific issues relating to refugees coming to Phnom Penh at the time, but she did notice that "the country was in trouble." Her husband was briefly arrested as a "progressive" along with two professors, and she noticed new student protests taking place against Lon Nol.

[១២] Mom Sam Oeurn also testified that her father-in-law, who also lived with them at the time, left the house to investigate the source of the noises and never returned. She believed Khmer Rouge soldiers arrested him.

[១៣] Although early in her testimony, Mom Sam Oeurn explained that she "could not see anything" without her glasses, she responded to questioning from Beini Ye saying that she could still see things, just not as clearly. She also stated she attempted to use the broken glasses, but she also relied on her children's observations at the time.

[១៤] IR 76(7): Applications Concerning Procedural Defects. … 7. Subject to any appeal, the Closing Order shall cure any procedural defects in the judicial investigation. No issues concerning such procedural defects may be raised before the Trial Chamber or the Supreme Court Chamber.

[១៥] IR 55(7): A written record shall be made of every interview. Each page of the written record shall be signed or fingerprinted after the interviewee reads it. If necessary, the Greffier of the Co-Investigating Judges, with the assistance of the interpreter, shall read the record back. IF the interviewee refuses to sign or fingerprint the record, the Greffier of the Co-Investigating Judges shall not this on the record.

[១៦] This may refer to any interview, or only to an interview of the Accused, as in IR 25(1). The Prosecutor argued the latter in "Co-Prosecutors' Response to Ieng Sary's Request that the Trial Chamber Seek Clarification from the OCIJ as to the Questioning of Witness Norng Sophang on 17 February 2009 and Summon the OCIJ Investigators to Give Evidence Regarding this Interview" (8 October 2012). E234/1. par. 25-26. 8-9. The Ieng Sary defense argued the former in E241, par. 11. 3-4.

[១៧] Ieng Sary Defense. "Ieng Sary's Request for the Trial Chamber to Hold a Public Hearing and Take Evidence Concerning the OCIJ's Widespread and Systematic Practice of Conducting Unrecorded Interviews with Witnesses" (2 November 2012). E241[hereinafter **IENG SARY'S REQUEST**].

១៨ IR 93: Additional Investigations by the Trial Chamber. 1. Where the Chamber considers that a new investigation is necessary it may, at any time, order additional investigations. Such order shall indicate which judge or judges shall conduct the new investigation. 2. Such judge(s) may, under the same conditions as the Co-Investigation Judges: a) go anywhere within the territorial jurisdiction of the ECCC; b) interview witnesses; c) conduct searches; seise any evidence; or e) order expert opinions. 3. For the purposes of such additional investigations, the judge(s) may issue Rogatory Letters to the Judicial Police.

១៩ IENG SARY'S REQUEST, p. 2.

២០ The request specifically noted four previously-defined cases of unrecorded interviews of witnesses: those of Oeun Tan, Phy Phuon, Norng Sophang, and Sokh Chhin. IENG SARY'S REQUEST, para. 3-4.

២១ However, the IengSary defense team's submission seems to contain some interpretations of the Internal Rules that does not appear squarely in line with the language of the Rules. For example, the defense cited Rule 51(8) as delineating the specific information that must be included in such a record, including "the duration of any interview and the duration of any breaks between interview periods." (IENGSARY'S REQUEST, para 8.) Rule 51(8) does indeed describe the information that must be recorded in a report, and sub-part (g) includes the specific cited language. However, Rule 51(8) specifically refers to Co-Prosecutors' report of every arrest of a suspect. IR 51 sates: "Police Custody. (8) The Co-Prosecutors shall make a final report for every arrest, which shall include the following information: …(g) The duration of any interview and the duration of any breaks between periods."

២២ In the common law system, it is appropriate for a defense counsel to ask leading questions. However, it is not appropriate for the prosecution to ask leading questions. In the civil law system, it is not appropriate for any party to ask leading questions, as the purpose of the hearing is to ascertain the truth. The Cambodian legal system is a civil law system.

២៣ *The Prosecutor v. Pavle Strugar*. IT-01-42-A. ICTY Trial Chamber II."Decision Re the Defence Motion to Terminate Proceedings" (26 May 2004). [hereinafter, ***STRUGAR* TRIAL CHAMBER DECISION**].

២៤ *Strugar* Trial Chamber Decision, par. 2, "Capacities of an accused"; *The Prosecutor v. Pavle Strugar*. IT-01-42-A. ICTY Appeals Chamber. "Judgment" (17 July 2008). [hereinafter, ***STRUGAR* APPEALS CHAMBER JUDGMENT**], par. 41.

២៥ *Strugar* Trial Chamber Decision, par. 37.

២៦ *Strugar* Trial Chamber Decision. The Chamber also used the following vague language: a chamber must view the accused's capacities "overall and in a reasonable and commonsense manner" (par. 3); a decision on an accused's fitness is "merely the balance of probabilities" (par. 4); an accused must be able to "sufficiently" exercise his rights (par. 3) at a "minimum standard of overall capacity" (par. 37).

២៧ "The availability of counsel… may well adequately compensate for any deficiency of a relevant capacity." *Strugar* Trial Chamber Decision, par. 22; also cited in Trial Chamber Decision, par. 28. 11.

២៨ "The use of counsel requires, however, that the accused has the capacity to be able to instruct counsel sufficiently for this purpose." *Strugar* Trial Chamber Decision, par. 22; also cited in Trial Chamber Decision, par. 28. 11.